សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អភិបាលកិច្ចល្អនៅឃុំតានីស្រុកអង្គរជ័យ ខេត្តកំពតបច្ចុប្បន្ន

ស្រាវជ្រាវពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៦

ឈ្មោះស្ថាប័ន: ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត

រៀបរៀងឡើងដោយ

និស្សិតឈ្មោះ: **ជា ឆាវី**

សាស្ត្រាចារ្យណែនាំ

អនុបណ្ឌិត **ហៀង សាង**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី១៦

ឆ្នាំចូលរៀន ២០១២

ឆ្នាំសរសេររបាយការណ៍២០១៦

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំ សូមក្រាបប្រណិប័តន៍ ថ្លែងអំណរគុណដោយក្ដីកត្តញ្ញូតាធម៌ និង ដោយក្ដីគោរពដ៏ខ្ពង់ខ្ពស់ដល់លោកអ្នកដែលមានគុណដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅដល់រូបកូន ។

ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះលោកយាយ លោកតា លោកអ៊ុំប្រុស លោកអ៊ុំស្រី ពូមីង និង បងប្អូនប្រុស ស្រីរបស់ខ្ញុំទាំងអស់ដែលបានផ្ដល់ជាកម្លាំងចិត្តឲ្យនាងខ្ញុំរហូតមក ។

**សូមអនុញ្ញាតថ្លែងអំណរគុណជូន**

អ្នកមានគុណទី២របស់នាងខ្ញុំ គឺ សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញ ណែនាំ ផ្ដល់នូវចំណេះដឹង ចំណេះធ្វើចង្អុលបង្ហាញនូវមាគ៌ាដ៏ត្រចះត្រចង់មានតម្លៃ និង មានប្រយោជន៍ សម្រាប់អនាគតដ៏រុងរឿងដល់នាងខ្ញុំ ។

លោកសាស្ត្រាចារ្យ អនុបណ្ឌិត ហៀង សាង និង លោក មេឃុំ អ៊ីវ សួន នៃឃុំ តានី ស្រុក អង្គរជ័យ ខេត្តកំពត ព្រមទាំង សមាជិកក្រុមប្រឹក្សាឃុំ តានី ស្មៀនឃុំ មេភូមិ និង សមាជិកដទៃទៀត ដែលបានរួមសកម្មភាពជួយជ្រោមជ្រែងស្មារតី គំនិត និង យកចិត្តទុកដាក់ក្នុងដំណើរការស្រាវជ្រាវ ក្នុងការសរសេររបាយការណ៍ស្រាវជ្រាវ ក្រោមប្រធានបទស្ដីពី **អភិបាលកិច្ចល្អនៅឃុំតានីស្រុកអង្គរជ័យខេត្តកំពតបច្ចុប្បន្ន** នេះឲ្យសម្រេចបានជោគជ័យ ។

ជាចុងក្រោយនៃកថានេះ នាងខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្ដី ជ័យមង្គល កើតមានដល់អស់លោកអ្នកមានគុណទាំងឡាយ និង សូមឲ្យលោកជួបប្រទះ នូវ ពុទ្ធពរ ទាំងបួនប្រការ គឺ អាយុវណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ឃុំ គឺជាកម្លាំងរដ្ឋបាលសាធារណៈរបស់ជាតិយ៉ាងសំខាន់នៅក្នុងការអនុវត្តកម្មវិធីគោលនយោបាយជាតិ ។ ប្រសិនជាក្នុងប្រទេសមួយមិនមានការពង្រឹងគោលនយោបាយរបស់ខ្លួននៅថ្នាក់ឃុំ ទេនោះប្រទេសនោះច្បាស់ជាលំបាកក្នុងការធ្វើឲ្យមានប្រសិទ្ធភាព លើទិសដៅការងាររបស់ខ្លួនជាក់ជាមិនខាន ។ លើសពីនេះទៅទៀត សមាជិកនៅក្នុងឃុំ ក៏ប្រជាពលរដ្ឋនៅក្នុងប្រទេសផងដែរ ដូចនេះការបណ្តុះបណ្តាលស្មារតី និង គុណភាពការងារ នៅថ្នាក់ឃុំរបស់ជាតិសំខាន់ជាងនេះទៅទៀត គឺបានធ្វើឲ្យប្រជាពលរដ្ឋមានស្មារតីទទួលខុសត្រូវខ្ពស់ចំពោះសង្គមរបស់ខ្លួន និង ជាចំណុចសំខាន់មួយក្នុងការធ្វើឲ្យមានការរីកចម្រើននៅក្នុងសង្គម ក៏ដូចជារបស់ប្រជាជាតិនោះ ។

វត្ថុបំណង នៃការជ្រើសរើសយកប្រធានបទ អភិបាលកិច្ចល្អនៅឃុំតានីស្រុកអង្គរជ័យខេត្តកំពត មកសរសេរជារបាយការណ៍បញ្ចប់ការសិក្សារបស់រូបនាងខ្ញុំ គឺចង់បង្ហាញពីផ្នែកមួយនៃសកម្មភាពផែនការអភិវឌ្ឍន៍ឃុំ ភូមិសាស្ត្រ ប្រជាសាស្ត្រ សកម្មភាពការងារ លទ្ធផលការងារ បញ្ហាប្រឈម និង ទិសដៅសកម្មភាពការងារឆ្នាំ២០១៦ ក្នុងឃុំតានី មកបង្ហាញ និង ធ្វើឲ្យមានការយល់ដឹងផងដែរចំពោះសកម្មភាពការងារបច្ចុប្បន្ន និង ទិសដៅការងារនាពេលអនាគតរបស់ឃុំតានី ក្នុងការបម្រើប្រជាពលរដ្ឋ ។

ថ្វីត្បិតតែរបាយការណ៍ស្រាវជ្រាវឯកសារបញ្ចប់ការសិក្សានេះ បានលើកបង្ហាញពីសកម្មភាព ការងាររបស់សមាជិកក្រុមប្រឹក្សាក្នុងឃុំក៏ដោយ ប៉ុន្តែ ក៏នៅតែមិនអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋគ្រប់ជ្រុងជ្រោយនៃទិសដៅការងារ និង ទិសដៅសកម្មភាពរបស់ឃុំ ទាំងមូលដែរ ។

ដូច្នេះរបាយការណ៍ ក្នុងការស្រាវជ្រាវឯកសារបញ្ចប់ការសិក្សានេះ សូមអធ្យាស្រ័យផងដែរចំពោះរាល់ចំណុចខ្វះខាតទាំងឡាយណាដែលបានកើតមានឡើងចំពោះខ្លឹមសារ និង ការបកស្រាយនៅក្នុងរបាយការណ៍នេះ ។

# មាតិកា

**ទំព័រ**


**សេចក្ដីផ្ដើម**...................................................................................................1

## ជំពូកទី១៖ ស្ថានភាពទូទៅនៅឃុំតានី ស្រុកអង្គរជ័យ

**១.១.ស្ថានភាពភូមិសាស្ត្រ និង ស្ថានភាពប្រជាសាស្ត្រ**........................................4

**១.១.១.ស្ថានភាពភូមិសាស្ត្រ**............................................................................4

**១.១.២. ស្ថានភាពប្រជាសាស្ត្រ**..........................................................................5

**១.២. ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចល្អ**...........................................................5

**១.២.១. និយមន័យអភិបាលកិច្ចល្អ**.......................................................................6

**១.២.២. គោលការណ៍នៃអភិបាលកិច្ចល្អ**..............................................................6

**ទី១.ការចូលរួម**..........................................................................................6

**ទី២.នីតិរដ្ឋ**..................................................................................................7

**ទី៣.តម្លាភាព**..............................................................................................7

**ទី៤.ការព្រមព្រៀងឯកភាពគ្នា**........................................................................7

**ទី៥.សមធម៌**..................................................................................................8

**ទី៦.ប្រសិទ្ធភាព**..............................................................................................9

**ទី៧.គណនេយ្យភាព**..........................................................................................9

**ទី៨.ការឆ្លើយតប**..............................................................................................9

**ទី៩.ចក្ខុវិស័យជាយុទ្ធសាស្ត្រ**..............................................................................10

## ជំពូកទី២៖ សកម្មភាពការងាររបស់ឃុំតានីស្រុកអង្គរជ័យ

**២.១. តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ឃុំ**......................................................11

**២.១.១. តួនាទី ភារកិច្ច**..........................................................................................11

**២.១.២. រចនាសម្ព័ន្ធរបស់ឃុំ**....................................................................................13

**២.២. ភូមិឃុំមានសុវត្ថិភាព.**......................................................................................17

**២.៣. ប្រជាការពារ**...................................................................................................18

**២.៤. ការបង្កើតផែនការអភិវឌ្ឍន៍ឃុំ**...........................................................................19

២.២.១. សកម្មភាពប្រចាំឆ្នាំ២០១៥ .......... 20
ក. ផ្នែកសេដ្ឋកិច្ច .......... 20
ខ. ផ្នែកសង្គមកិច្ច .......... 20
គ. ផ្នែកធនធានធម្មជាតិ និងបរិស្ថាន .......... 20
ឃ.ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ .......... 21
ង. ផ្នែកយេនឌ័រ .......... 22
ជំពូកទី៣៖ លទ្ធផលការងារ បញ្ហាប្រឈម និងទិសដៅសកម្មភាពឆ្នាំ២០១៦
៣.១. លទ្ធផលការងាររបស់ឃុំ .......... 23
៣.១.១. សភាពការណ៍រួម .......... 23
៣.១.២. លទ្ធផលនៃកិច្ចប្រតិបត្តិការតាមផ្នែកនីមួយៗ .......... 23
ក. លទ្ធផលនៃកិច្ចប្រតិបត្តិការផ្នែកសេដ្ឋកិច្ច .......... 23
ក.១. កសិកម្ម .......... 23
ក.២. សកម្មភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវលំជនបទ .......... 24
ក.៣. សកម្មភាពការងារធនធានទឹក .......... 25
ក.៤. ផ្នែកឧស្សាហកម្ម និងថាមពល .......... 25
ខ.លទ្ធផលនៃកិច្ចប្រតិបត្តិការផ្នែកសង្គមកិច្ច .......... 25
ខ.១. ការងារផ្នែកវិស័យអប់រំ .......... 25
ខ.២. សកម្មភាពផ្នែកសុខាភិបាល .......... 26
ខ.៣. សកម្មភាពផ្នែកអភិវឌ្ឍន៍ជនបទ .......... 26
ខ.៤. កិច្ចការសង្គម .......... 26
គ. លទ្ធផលនៃកិច្ចប្រតិបត្តិការផ្នែកធនធានធម្មជាតិ និងបរិស្ថាន .......... 27
គ.១. ការគ្រប់គ្រងដីធ្លី .......... 27
គ.២. ធនធានធម្មជាតិ និងបរិស្ថាន .......... 27
គ.៣. ការប្រែលប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ .......... 27
ឃ.លទ្ធផលនៃកិច្ចប្រតិបត្តិការផ្នែកសេវារដ្ឋបាល និងសន្តិសុខ .......... 27
ឃ.១. ផ្នែករដ្ឋបាល .......... 27
ឃ.២. ផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ .......... 28
ង.លទ្ធផលនៃកិច្ចប្រតិបត្តិការផ្នែកយេនឌ័រ .......... 28

៣.២.បញ្ហាប្រឈម....................................................................................................29
៣.៣. ទិសដៅសកម្មភាពឆ្នាំ២០១៦ ........................................................................................ 31
សេចក្តីសន្និដ្ឋាន
អនុសាសន៍
ឯកសារយោង
បញ្ជីឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ឃុំ តានី ជានីតិបុគ្គល និង ជាសមូហភាពដែនដីរបស់រដ្ឋ ក្នុងការបម្រើសេវាកម្មរដ្ឋបាលសាធារណៈជូនប្រជាពលរដ្ឋ ស្របទៅតាមឋានានុក្រម ខេត្ត ក្រុង ស្រុក ឃុំ ក្នុងគោលបំណងធានាសន្តិសុខ សណ្តាប់ធ្នាប់ និង ភាពសុខដុមរមនារបស់ប្រជាពលរដ្ឋក្នុងសង្គម ។ សម្រាប់ប្រទេសកម្ពុជា ឃុំ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩០៣ ១៩០៤ ដោយអាណានិគមបារាំង ហើយត្រូវបានបញ្ជាក់ជាបន្តបន្ទាប់ ដោយព្រះរាជប្រកាស ០៥/០៦/១៩០៨, ២៤/០៨/១៩១៩ ហើយជាពិសេសនោះគឺ ដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់ជំពូកទី១៣ មាត្រា១៤៥[១] ។ នាពេលបច្ចុប្បន្នរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ ជាស្ថាប័នមួយដែលធ្វើការគ្រប់គ្រង និង បម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋដែលស្ថិតនៅក្នុងមូលដ្ឋានភូមិ ឃុំរបស់ខ្លួនទូទាំងប្រទេស ។

ផ្អែកតាមការវិវឌ្ឍន៍នៃស្ថានភាពប្រែលប្រួលនៃប្រទេសកម្ពុជា ដើម្បីពង្រឹង និង ពង្រីកប្រសិទ្ធភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅក្នុងមូលដ្ឋានឃុំតានី បានកំណត់ និង ដាក់ចេញនូវទស្សនវិស័យ ការអនុវត្ត និង បានរំពឹងទុកចំពោះសមិទ្ធផលដែលត្រូវបានទទួលក្នុងឆ្នាំ២០១៦ តាមរយៈផែនការអភិវឌ្ឍន៍ គ្រប់ផ្នែកទាំងអស់របស់ខ្លួន ។ តាមរយៈផែនការអភិវឌ្ឍន៍ និង ទិសដៅសកម្មភាពនេះ បានរំលេចឲ្យឃើញពីតម្រូវការ នៃការចូលរួមសហការរបស់ប្រជាពលរដ្ឋ ជាមួយឃុំ ក្រុមប្រឹក្សាឃុំ ដែលជាការរួមចំណែកជួយជ្រោមជ្រែងលទ្ធភាពការងាររបស់ឃុំ ឲ្យឈានទៅសម្រេចបានជោគជ័យ ។

ហេតុនេះហើយ ការយល់ដឹងរបស់ប្រជាពលរដ្ឋពី អភិបាលកិច្ចល្អនៅក្នុងមូលដ្ឋានឃុំ ពិតជារឿងចាំបាច់ និង ជាការចូលរួមចំណែកលើកស្ទួយ អភិបាលកិច្ចល្អ ក្នុងវិស័យអភិវឌ្ឍន៍ រៀបចំរបៀបរៀបរយ និង រក្សាការពារសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់សង្គមទាំងមូលក្នុងមូលដ្ឋានឃុំ ក៏ដូចជាការផ្តល់សេវាផ្សេងៗ ដែលជាសមត្ថកិច្ចរបស់ឃុំតានី ជាពិសេសការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានភូមិឲ្យទាន់ពេលវេលា និង មានប្រសិទ្ធភាព ។

ស្របតាមស្ថានភាពខាងលើ ប្រទេសកម្ពុជាចាំចាច់ត្រូវមានឃុំ ដែលពោរពេញទៅដោយសមត្ថភាព និង មានការទទួលខុសត្រូវខ្ពស់ ទើបមានការទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ និង អាចធានាបាននូវប្រសិទ្ធភាពការងារ ក្នុងការអនុវត្តសកម្មភាព និង គោលការណ៍របស់ខ្លួន ហើយអាចគ្រប់គ្រងស្ថានភាពចាំបាច់នៅក្នុងឃុំ ក្នុងពេលដែលសកម្មភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ ពុំមាន

[១] ជំពូកទី១៣ មាត្រា១៤៥ នៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៩៣

ភាពចុះសម្រុងគ្នាទៅលើបញ្ហាដែលបានលើកឡើង ហើយបញ្ហានេះគឺជាតម្រូវការរបស់ប្រជាពលរដ្ឋបានស្នើសុំ នោះអាចបណ្តាលឲ្យមានការមិនពេញចិត្តពីសំណាក់ប្រជាពលរដ្ឋ ដោយសារទង្វើមិនគួរគប្បីរបស់សមាជិកក្រុមប្រឹក្សាឃុំ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ហើយទន្ទឹមនឹងនេះការបាក់ទឹកចិត្ត និង ការបាត់អស់ជំនឿចិត្ត ក៏កើតមានឡើងចំពោះឃុំដទៃទៀត ដែលបានខិតខំពុះពារឧបសគ្គ យ៉ាងលំបាកក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដើម្បីជួយមូលដ្ឋានឃុំ ក្នុងសង្គមជាតិនៃប្រទេសកម្ពុជាឲ្យរួមរស់ជាមួយគ្នាបានសុខសាន្ត ។ ជាងនេះទៅទៀតបញ្ហាដែលកើតមានស្រាប់នោះ គឺបានជះឥទ្ធិពលដល់ប្រសិទ្ធភាពក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ក្នុងគោលនយោបាយជាតិ ជាពិសេសចំពោះ វិស័យរដ្ឋបាលសាធារណៈ និង សន្តិសុខរបស់ឃុំ ក្នុងប្រទេសកម្ពុជាទាំងមូលផងដែរ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ឃុំ តានី ស្រុកអង្គរជ័យ ខេត្តកំពតដោយគោរពតាមផែនការកម្មវិធីវិនិយោគរបស់ឃុំ បានបង្ហាញពីការដឹកនាំអភិវឌ្ឍន៍ដែលមានលក្ខណៈច្បាស់លាស់ ត្រឹមត្រូវ ។ ថ្វីត្បិតតែ របាយការណ៍ស្រាវជ្រាវឯកសារនេះ បានបង្ហាញអំពីការងារត្រឹមកម្រិតឃុំក៏ពិតមែន តែបានឆ្លុះបញ្ចាំងនូវទិសដៅសកម្មភាពនៃឃុំ ចំពោះការចូលរួមយ៉ាងសកម្ម ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ ឲ្យមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងមានការខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាឃុំ ទូទាំងស្រុកអង្គរជ័យខេត្តកំពតផងដែរ ។

## ៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

របាយការណ៍ស្រាវជ្រាវឯកសារក្រោមប្រធានបទ អភិបាលកិច្ចល្អ នៅឃុំតានី ស្រុកអង្គរជ័យខេត្តកំពតបច្ចុប្បន្ន បានលើកបង្ហាញអំពីសកម្មភាពការងារជាច្រើនដែលគ្រប់ផ្នែកទាំងអស់ គឺស្ថិតក្រោមការដឹកនាំរបស់មេឃុំ ប្រធានក្រុមប្រឹក្សាឃុំបានអនុវត្ត និង សម្រេចជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានភូមិ ឃុំ និង ការងារសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការតាមដាន និង វាយតម្លៃដើម្បីឈានទៅរកភាពរីកចម្រើនទូទាំងឃុំតានី ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ដើម្បីបំផុសការយល់ដឹងជាសាធារណៈ ទៅកាន់ប្រជាពលរដ្ឋទូទៅ និង សិស្សនិស្សិត ឲ្យមានការយល់ដឹងអំពីផ្នែកមួយនៃគោលនយោបាយជាតិ ចំពោះក្រុមប្រឹក្សាឃុំ តានី ក៏ដូចជាការលើកកំពស់ស្មារតីទទួលខុសត្រូវខ្ពស់របស់ឃុំ តានី ផងដែរ ។ ហើយខ្ញុំមានជំនឿថា របាយការណ៍ស្រាវជ្រាវឯកសារនេះ គឺប្រៀបដូចជាអ្នកនាំពាក្យ របស់ឃុំ ក្នុងការចេញមុខការពារតម្លៃ សកម្មភាព

រួមទាំងអស់គ្នា បម្រើប្រជាពលរដ្ឋ និង មានទស្សនៈវិស័យរួមគ្នាដើម្បីភាពរីកចម្រើនកម្ពុជារបស់ឃុំជាតិកម្ពុជា ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ ត្រូវបានបង្កើតឡើងដោយប្រមូលផ្តុំនូវឯកសារមួយចំនួនដែលទាក់ទងទៅនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង ផ្អែកលើទិន្នន័យនៃរបាយការណ៍បូកសរុបសមិទ្ធផលប្រចាំឆ្នាំ នៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ ព្រមទាំងច្បាប់ និង បទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនទៀត ។ ហើយក៏មានការសិក្សាស្រាវជ្រាវបន្ថែមដោយប្រមូលយកព័ត៌មានមួយចំនួន ដែលបានមកពី ការសិក្សារៀនសូត្រលើមេរៀនកន្លងមក និង ការចុះទៅសិក្សាផ្ទាល់នៅឃុំតានីផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើការបកស្រាយទៅលើការស្រាវជ្រាវមួយនេះ ជាដំបូងខ្ញុំសុំបង្ហាញពីការបែងចែកប្លង់នៃការសិក្សាស្រាវជ្រាវនេះជាមុនសិន ជាក់ស្តែងសារណាមួយនេះត្រូវបានបែងចែកជា ៣ជំពូក រួមមាន៖

**ជំពូកទី១** ៖ បង្ហាញពី ស្ថានភាពទូទៅនៅឃុំតានី ស្រុកអង្គរជ័យ ដោយបានលើកឡើងពី ស្ថានភាពភូមិសាស្ត្រ ស្ថានភាពប្រជាសាស្ត្រ និង ទិដ្ឋភាពទូទៅជុំវិញក្របខណ្ឌនៃអភិបាលកិច្ចល្អ ។

**ជំពូកទី២** ៖ បង្ហាញពី សកម្មភាពការងាររបស់ឃុំតានី ដោយបានលើកឡើងពី តួនាទី ភារកិច្ច រចនាសម្ព័ន្ធ និង ការបង្កើតផែនការអភិវឌ្ឍន៍ឃុំតានី ។

**ជំពូកទី៣** ៖ លទ្ធផលការងារ បញ្ហាប្រឈម និងទិសដៅសកម្មភាពឆ្នាំ២០១៦ ដោយបានលើកឡើងពី លទ្ធផលការងារតាមផ្នែកនីមួយៗ បញ្ហាប្រឈមដែលឃុំមិនទាន់បានដោះស្រាយ និង ទិសដៅ សកម្មភាពបន្តសម្រាប់ឆ្នាំ២០១៦ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងឃុំតានី ។

# ជំពូកទី១

# ស្ថានភាពទូទៅនៅឃុំតានី ស្រុកអង្គរជ័យ

## ១.១.ស្ថានភាពភូមិសាស្ត្រ និង ប្រជាសាស្ត្រ

ភូមិសាស្ត្រ និង ប្រជាសាស្ត្រ គឺជាកត្តាដ៏សំខាន់ក្នុងការបង្កើតផែនការ ឬ ទិសដៅសកម្មភាពផ្សេងៗរបស់ភូមិ ឃុំដែលមានសមត្ថកិច្ចពាក់ព័ន្ធ ។ ព្រោះថាការស្វែងយល់ពីកត្តាទាំងនេះអាចឲ្យថ្នាក់ដឹកនាំ ឬ អ្នកទទួលភារកិច្ចនោះបានដឹង និង ស្វែងយល់បានពីតម្រូវការជាក់ស្តែង និង បញ្ហាដែលកើតមានឡើងក្នុងភូមិសាស្ត្រនោះអាចត្រៀម ឬ លើកផែនការដើម្បីឆ្លើយតបជាមួយសភាពការណ៍ទាំងនោះក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាព ។

ដូច្នេះការស្វែងយល់ឲ្យបានស៊ីជម្រៅអំពីផ្នែកភូមិសាស្ត្រ និង ប្រជាសាស្ត្រនៃតំបន់មួយគឺពិតជាមានសារៈសំខាន់ និង មិនអាចមើលរំលងបានឡើយ។ យ៉ាងណាមិញ ប្រជាជនទាំងនោះគឺ៖

- មានបញ្ហាផ្សេងៗគ្នា
- មានតម្រូវការចាំបាច់ផ្សេងគ្នា
- មានចំណេះដឹង
- មានការប្រកបរបរចិញ្ចឹមជីវិត
- មានកម្រិតជីវភាព
- និងការទទួលបានផលប្រយោជន៍ពីការរីកចម្រើនរបស់ឃុំខុសៗគ្នាទាំងអស់។

កត្តាទាំងនេះគឺបានជះឥទ្ធិពល និង ពាក់ព័ន្ធដល់ការងារអភិវឌ្ឍន៍របស់ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពតទាំងមូល។

### ១.១.១. ស្ថានភាពភូមិសាស្ត្រ

តានី គឺជាឈ្មោះឃុំរបស់ស្រុកអង្គរជ័យខេត្តកំពតដែលស្ថិតនៅប៉ែកខាងត្បូងជាប់នឹងទីរួមស្រុកអង្គរជ័យ ។ ដំបូងឡើយឃុំតានី គឺជាឃុំភ្នំកុងដែលស្ថិតនៅ ស្រុកអង្គរជ័យ ខេត្តកំពតដែរ តែនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៨១ ក៏បានបំបែកឈ្មោះទៅជាឃុំតានី ហើយតានីនេះផងដែរ គឺបកប្រែចេញពីភាសាចិន ដែលមានន័យថា« មិត្តសំឡាញ់ ឬ ពួកម៉ាក» ដែលបច្ចុប្បន្នត្រូវបាន គេហៅថា ឃុំតានី មានចម្ងាយ ៧១Km ពីទីរួមខេត្តកំពត និង មានចម្ងាយ ១០១Km ពីរាជធានីភ្នំពេញ ដោយធ្វើដំណើរចេញពីភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ ០៣ រហូតដល់ចំណុចថ្នល់បែកគូស បត់ឆ្វេងទៅតាមបណ្តោយផ្លូវជាតិលេខ ៣១ ត្រង់គីឡូម៉ែត្រលេខ ៨២ ។

សព្វថ្ងៃឃុំតានីមានផ្ទៃដីរួមសរុប ២.៥៣០ហិចតា មានភូមិចំនួន០៧ភូមិ គឺ៖

- ភូមិប្រាល

- ភូមិត្រពាំងរុន
- ភូមិត្រពាំងរាំង
- ភូមិតាព្រាម
- ភូមិកាន់ទ្រង់
- ភូមិតាកុក
- ភូមិឫស្សី។

ឃុំតានី មានព្រំប្រទល់៖

- ខាងកើតទល់នឹងឃុំសន្លុងខេត្តតាកែវ
- ខាងលិចទល់នឹងជួរភ្នំសែនហាន
- ខាងត្បូងទល់នឹងឃុំភ្នំកុង
- និងខាងជើងទល់នឹងឃុំអង្គរជ័យ ដែលជាឃុំក្នុងស្រុកអង្គរជ័យខេត្តកំពត។

រីឯផ្នែកហេដ្ឋារចនាសម្ព័ន្ធ គឺមានការរីកចម្រើនគួរឲ្យគត់សម្គាល់ដោយនៅតាមភូមិនីមួយៗ គឺមានផ្លូវលំក្រាលគ្រួសក្រហម ផ្លូវលំដីស សម្រាប់ប្រជាពលរដ្ឋធ្វើដំណើរគ្រប់គ្រាន់ ។ ក្រៅពីនេះ សំណង់អគារសាលារៀន វត្តអារាមជាច្រើនរបស់ឃុំបានបន្តសង់ និង កែលម្អឲ្យមានភាពល្អប្រសើរ ឡើងទៀតផង ។

### **១.១.២. ស្ថានភាពប្រជាសាស្ត្រ**

បច្ចុប្បន្នឃុំតានី មានប្រជាពលរដ្ឋរស់នៅសរុបចំនួន ១១.១៤៨នាក់ ស្មើនឹង ២.៣៨៦គ្រួសារ ក្នុងនោះស្រី ៥.៨៦៨នាក់ អាយុ១៨ឆ្នាំឡើងមានប្រុស ៣.៤០៤នាក់ និង ស្រី ៣.៧៩៥នាក់ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ ៦% ក្នុងមួយឆ្នាំ ប្រជាជនធ្វើចំណាកស្រុកនៅក្នុងប្រទេស មានចំនួន ៦៦៨ នាក់ និង ធ្វើចំណាកស្រុកក្រៅប្រទេសមានចំនួន ១៩៣នាក់។

ប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរ កសិកម្ម ធ្វើស្រែចំការ នេសាទ និង ចិញ្ចឹមសត្វ។ ប្រជាពលរដ្ឋក្នុងឃុំតានីគោរព ឥស្លាមសាសនា គ្រិស្ត៏សាសនា និង ព្រះពុទ្ធសាសនា ប៉ុន្តែ ភាគច្រើននៃប្រជាពលរដ្ឋក្នុងឃុំតានីគោរពព្រះពុទ្ធសាសនា។

## **១.២. ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចល្អ**

អភិបាលកិច្ចល្អ ត្រូវបានកំណត់យ៉ាងទូលំទូលាយ នៅក្នុងក្របខណ្ឌផ្សេងៗគ្នាជាច្រើន ក្នុងនោះក៏មាននៅក្នុងក្របខណ្ឌនយោបាយ និង ក្របខណ្ឌច្បាប់ ។ អភិបាលកិច្ចល្អនៅក្នុងក្របខណ្ឌច្បាប់ បានលើកបង្ហាញអំពីការគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋាននៅឃុំរបស់ខ្លួន បម្រើផល

ប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និង គោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ[២]។

**១.២.១. និយមន័យអភិបាលកិច្ចល្អ**

ការស្វែងយល់អំពីអភិបាលកិច្ចល្អ ទោះក្នុងក្របខណ្ឌណាក៏ដោយ គឺផ្អែកសំខាន់លើវិធីសាស្ត្រក្នុងការគ្រប់គ្រង និង ប្រើប្រាស់ធនធានទាំងឡាយរបស់អង្គភាព ឬ ស្ថាប័ន ដើម្បីបម្រើផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋឲ្យចំទិសដៅ និង ទទួលបានប្រសិទ្ធភាពខ្ពស់[៣]។

ក្នុងកម្មវិធីអភិវឌ្ឍន៍អភិបាលកិច្ចរបស់អង្គការសហប្រជាជាតិ ត្រូវបានដាក់ចេញនៅក្នុងរបៀបវារៈ អភិវឌ្ឍន៍ថ្មីប្រកបដោយនិរន្តរភាព ដែលមានគោលបំណងដើម្បីបញ្ចប់ភាពក្រីក្រ លើកកំពស់ភាពរុងរឿង និង សុខមាលភាពរបស់ប្រជាជន[៤]។

**១.២.២. គោលការណ៍នៃអភិបាលកិច្ច**

ដើម្បីឲ្យទ្រឹស្តី អភិបាលកិច្ចល្អទទួលបានលទ្ធផល គឺត្រូវរំលេចចេញជាគោលការណ៍ ដែលត្រូវអនុវត្តតាម ។ ហើយតាមរយៈគោលការណ៍នេះ គឺអាចធ្វើការវាយតម្លៃលើការងារសម្រេចបាន ឬ កម្រិតនៃការទទួលខុសត្រូវ ក៏ដូចជាកម្រិតនៃភាពរីកចម្រើន របស់សង្គមទៅដល់ប្រជាពលរដ្ឋបានទៀតផង ។ គោលការណ៍នៃអភិបាលកិច្ចល្អ ជាទូទៅគឺបានរំលេចឡើងនូវលក្ខណៈ៩ចំណុចដូចខាងក្រោម៖

**ទី១.ការចូលរួមពីគ្រប់ភាគីដែលពាក់ព័ន្ធ** មានន័យថា ការចូលរួមរបស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច និង ការអនុវត្តសេចក្តីសម្រេចនោះតាមរយៈអ្នកតំណាងក្តី ឬ ដោយផ្ទាល់ក្តី គឺពិតជាសំខាន់បំផុតក្នុងការធានាថា ព័ត៌មានទាំងឡាយស្តីពីបញ្ហា និង តម្រូវការផ្សេងៗត្រូវបានប្រមូលយកមកធ្វើការវិភាគបានល្អិតល្អន់អំពីព័ត៌មានទាំងនោះ ។ អាចធ្វើឲ្យក្រុមងាយរងគ្រោះ ឬ ក្រុមភាគតិច បានបង្ហាញអំពីផលប៉ះពាល់នានា ឬ តម្រូវការជាក់ស្តែងរបស់ពួកគេ ចូលទៅក្នុងការពិភាក្សាមុន និង ធ្វើសេចក្តីសម្រេចអំពីអ្វីមួយផងដែរ ។

**ការចូលរួមដោយផ្ទាល់** គឺមានន័យថា ប្រជាពលរដ្ឋខ្លួនឯង ត្រូវចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចនោះផ្ទាល់តែម្តង ។ ហើយការចូលរួមដោយផ្ទាល់របស់ប្រពលរដ្ឋអាចធ្វើឡើងតាម

---

[២] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ចំណុច"អភិបាលកិច្ចល្អក្របខណ្ឌច្បាប់" ទំព័រទី២៣

[៣] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ទំព័រទី៣

[៤] http://www.undp.org

រយៈការបង្កើតសហគមន៍ សមាគមនានា ការឈរឈ្មោះបោះឆ្នោត ឬ ការបញ្ចេញកម្លាំងពលកម្ម និង ធនធានរបស់ប្រជាពលរដ្ឋផ្ទាល់សម្រាប់ដំណើរការអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់ខ្លួន ។

**ការចូលរួមតាមរយៈអ្នកតំណាង** គឺមានន័យថា ប្រជាពលរដ្ឋអាចមានអ្នកតំណាងរបស់ពួកគាត់ ដើម្បីចូលរួមក្នុងដំណើរការពិភាក្សាផ្សេងៗដែលពាក់ព័ន្ធជាមួយពួកគាត់ហើយអ្នកតំណាងគឺត្រូវតំណាងឲ្យឆន្ទៈ និង ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ។ អ្នកតំណាង គឺត្រូវបានប្រជាពលរដ្ឋជ្រើសរើសតាមរយៈវិធីផ្សេងៗដូចជា តាមរយៈការបោះឆ្នោតជាសកល ឬ អសកលជាដើម ។ ចំណុចនេះគឺភាគច្រើនសំដៅលើសមាជិក រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**ទី២.នីតិរដ្ឋ** ក្នុងន័យ**អភិបាលកិច្ចល្អ** មានន័យថា គឺជាសង្គមដែលមានក្របខណ្ឌច្បាប់គ្រប់គ្រាន់ក្នុងការគ្រប់គ្រង និង ការពារផលប្រយោជន៍ទូទៅ ហើយមនុស្សគ្រប់រូបនៅក្នុងសង្គម គឺស្ថិតក្រោមច្បាប់ទាំងអស់គ្នា គឺចង់សំដៅដល់ការ ការពារសិទ្ធិមនុស្ស ជាពិសេសក្រុមងាយរងគ្រោះ ឬ ក្រុមភាគតិចដែលច្បាប់ត្រូវអនុវត្តដោយមិនលំអៀង ។ លើសពីនេះទៅទៀតនោះ គឺការមានប្រព័ន្ធទទួលខុសត្រូវយុត្តិធម៌ និង សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដែលអាចជឿទុកចិត្តបាន ។

**ទី៣.តម្លាភាព** ក្នុងន័យ**អភិបាលកិច្ចល្អ** មានន័យថា រាល់ការសម្រេចចិត្ត និង ការអនុវត្តសេចក្តីសម្រេចនោះ ត្រូវធ្វើឡើងដោយអនុលោមទៅតាមច្បាប់ បទដ្ឋាននានា និង ត្រូវផ្សព្វផ្សាយជាចំហតាមរយៈប្រព័ន្ធសមស្របមួយទៅកាន់អ្នកដែលទទួលរងនូវផលប៉ះពាល់ទាំងអស់ មុននឹងធ្វើការសម្រេចចិត្ត[៥]។

ការផ្សព្វផ្សាយជាចំហអំពីព័ត៌មានទាំងនោះត្រូវមានលក្ខណៈគ្រប់គ្រាន់ច្បាស់លាស់ និង ងាយស្រួលក្នុងការស្វែងយល់ ហើយទាន់ពេលវេលាដោយមិនយឺតយ៉ាវឡើយ។

<u>**ឧទាហរណ៍:**</u> ក្រុមប្រឹក្សាឃុំ ពេលធ្វើការសម្រេចចិត្តអំពីអ្វីមួយត្រូវធ្វើដោយបើកចំហ និង ផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធទៅនឹងការសម្រេចចិត្តនោះ ទៅកាន់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំរបស់ខ្លួនឲ្យទាន់ពេលវេលា និង ធានានូវភាពជាក់លាក់អំពីព័ត៌មាននោះ ដើម្បីបញ្ចៀស និង កាត់បន្ថយរាល់ការសង្ស័យ និង ការប្រព្រឹត្តអំពើពុករលួយក្នុងការសម្រេចនោះ។

**ទី៤.ការព្រមព្រៀងឯកភាពគ្នា** ក្នុងន័យ**អភិបាលកិច្ចល្អ** មានន័យថា រាល់ការធ្វើសេចក្តីសម្រេចអ្វីមួយគឺគេធ្វើការពិចារណាលើផលប្រយោជន៍ និង តម្រូវការរបស់អ្នកពាក់ព័ន្ធ ដោយមានការព្រមព្រៀងឯកភាពគ្នាលើជម្រើស និង វិធីសាស្ត្រល្អណាមួយដែលបម្រើផលប្រយោជន៍រួម ។

[៥] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ចំណុចតម្លាភាពទំព័រទី១៣

គោលការណ៍ណែនាំសម្រាប់សម្របសម្រួលឲ្យមានការព្រមព្រៀងឯកភាពគ្នា:[៦]

**ក.លក្ខខណ្ឌនៃការព្រមព្រៀងឯកភាពគ្នា**

លក្ខខណ្ឌនៃការព្រមព្រៀងឯកភាពគ្នារួមមាន:

- ការព្រមព្រៀងគ្នាប្រកបដោយសុខដុមរមនា
- ការពិគ្រោះយោបល់ជាមួយក្រុមពាក់ព័ន្ធទាំងអស់
- ការចូលរួមពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗ ក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត
- ការយល់ដឹងអំពីគ្នាទៅវិញទៅមក រវាងក្រុមពាក់ព័ន្ធទាំងអស់

**ខ.ដំណើរការនៃការព្រមព្រៀងឯកភាពគ្នា**

ខាងក្រោមនេះជាការណែនាំខ្លះៗ ដើម្បីធ្វើការសម្រុះសម្រួលឲ្យមានការព្រមព្រៀងឯកភាពគ្នា:

- រៀបចំឲ្យមានការជួបជុំគ្នារវាងក្រុមពាក់ព័ន្ធទាំងអស់
- ស្វែងយល់គ្នាទៅវិញទៅមករវាងក្រុមអ្នកពាក់ព័ន្ធទាំងអស់ និង បង្កើតការយោគយល់គ្នា
- ពិភាក្សាជាមួយក្រុមពាក់ព័ន្ធទាំងអស់អំពីផលប្រយោជន៍ និង បង្កើតជម្រើសនានា
- សម្រុះសម្រួល ដើម្បីសម្រេចយកជម្រើសល្អមួយ ដែលបម្រើនូវផលប្រយោជន៍រួមដោយមានការព្រមព្រៀងឯកភាពគ្នាប្រកបដោយសុខដុមរមនា ។

**<u>ឧទាហរណ៍:</u>** ក្រុមប្រឹក្សាឃុំតានី លើកគ្រោងសាងសង់ផ្លូវក្រាលគ្រួសក្រហមក្នុងភូមិឫស្សី គម្រោងសាងសង់នេះអាចធ្វើទៅបាន លុះត្រាណាតែមានការព្រមព្រៀងឯកភាពគ្នាពីសំណាក់ក្រុមប្រឹក្សាឃុំ និង ប្រជាពលរដ្ឋក្នុងភូមិឫស្សីទាំងមូលដែលមានផ្ទះ និង ទ្រព្យសម្បត្តិដូចជា ដើមដូង ដើមស្វាយ នៅអមសងខាងផ្លូវនោះ ហើយការសាងសង់ក៏ពុំមានផលប៉ះពាល់ដល់ផ្ទះ និង ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋផងដែរ ។

**ទី៥.សមធម៌** ក្នុងន័យ**អភិបាលកិច្ចល្អ** មានន័យថា ក្រុម ឬជនគ្រប់រូបទាំងអស់ជាពិសេស ក្រុមភាគតិច និង ក្រុមងាយរងគ្រោះ មានឱកាសគ្រប់គ្រាន់នៅក្នុងការចូលរួមបញ្ចេញយោបល់ លើកឡើងនូវតម្រូវការពិត អនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្រប ដើម្បីកែលំអ និង ថែរក្សាសុខុមាលភាពរបស់ពួកគេ ។ លើលពីនេះទៅទៀតអាចឲ្យពួកគេមានអារម្មណ៍ថា ពួកគេគឺជាសមាជិកពិតប្រាកដរបស់សង្គម និង មិនត្រូវបានសង្គមបោះបង់ចោលនោះទេ[៧] ។

---

[៦] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃចំណុចការព្រមព្រៀងឯកភាពគ្នា ទំព័រទ១៤ ដល់ទំព័រទី១៥

[៧] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃចំណុចសមធមិទំព័រ១៥

សុខុមាលភាពរបស់មនុស្ស សំដៅជាពិសេសលើភាពសប្បាយរីករាយ សុវត្ថិភាព ភាពសុខស្រួល បញ្ញាសន្តិសុខ សុខភាពល្អ ។ល។ សុខុមាលភាពរបស់មនុស្សម្នាក់ៗ គឺមិនគ្រាន់តែសំដៅលើផ្នែករូបកាយប៉ុណ្ណោះទេ ការគាំពារដល់ស្មារតី អារម្មណ៍ផ្លូវចិត្ត របស់មនុស្សទៀតផង ។ ហើយតាមរយៈនេះ ក៏បានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការបញ្ចេញមតិយោបល់ ទាក់ទងដល់តម្រូវការជាក់ស្តែងរបស់ក្រុមភាគតិច និង ជនងាយរងគ្រោះទាំងអស់ដែរ ។

**ទី៦.ប្រសិទ្ធភាព** ក្នុងន័យ**អភិបាលកិច្ចល្អ** គឺមានន័យថា រាល់ដំណើរការនៃការធ្វើសេចក្តីសម្រេច និង ការអនុម័តលទ្ធផលទាំងអស់ ត្រូវឆ្លើយតបជាមួយសភាពការណ៍ជាក់ស្តែង និង ទទួលបានប្រសិទ្ធភាពខ្ពស់ ហើយលើសពីនេះទៀត ត្រូវប្រើប្រាស់រាល់សមិទ្ធផលទាំងនោះឲ្យបានត្រឹមត្រូវ អាចបម្រើផលប្រយោជន៍រួមជាអតិបរមា ដោយភ្ជាប់ជាមួយការសន្សំសំចៃ ហើយការប្រើប្រាស់ធនធានធម្មជាតិ ធនធានហិរញ្ញវត្ថុ និង ធនធានផ្សេងៗទៀតរបស់ អង្គភាព ស្ថាប័ន ប្រកបដោយនិរន្តរភាព ។

**ទី៧.គណនេយ្យភាព** ក្នុងន័យ**អភិបាលកិច្ចល្អ** មានន័យថា គឺការទទួលខុសត្រូវ របស់អ្នកដែលត្រូវអនុវត្តតួនាទី និង ភារកិច្ចនៅក្នុងដំណើរការនៃការអនុវត្តសេចក្តីសម្រេចនោះ ដោយរាយការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុ នូវអ្វីដែលខ្លួនបានសម្រេច និង អនុវត្តនោះ[៥] ។ ហើយគណនេយ្យភាពនេះ គឺត្រូវធ្វើចំពោះថ្នាក់ដឹកនាំរបស់ខ្លួន និង ចំពោះមុខសាធារណៈជន ជាពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់អំពីការសម្រេចចិត្តនេះ ។

__**ឧទាហរណ៍:**__ ស្មៀនឃុំ ទទួលធ្វើសំបុត្រអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និង ខ្មែរ មួយច្បាប់ចំនួន ១៥.០០០៛ ពីគ្រួសារមួយ និង ធ្វើសំបុត្រអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និង ជនជាតិបរទេសមួយច្បាប់ដូចគ្នាចំនួន៣០.០០០៛ ពីគ្រួសារមួយ ការបង់ថ្លៃសេវាជាក់លាក់មិនស្មើគ្នាឡើយចំពោះគ្រួសារទាំងពីរនោះ ហើយស្មៀនឃុំត្រូវបង្ហាញបំភ្លឺនៃនីតិវិធីក្នុងការបង់ថ្លៃសេវានេះ ទៅគ្រួសារទាំងពីរនោះឲ្យបានយល់ច្បាស់ អំពីការខុសគ្នាក្នុងការបង់ថ្លៃសេវានេះ ។

**ទី៨.ភាពឆ្លើយតប** ក្នុងន័យ**អភិបាលកិច្ចល្អ** មានន័យថា ជាការព្យាយាម ខិតខំប្រឹងប្រែងរបស់អង្គភាព ស្ថាប័ន ដើម្បីបម្រើដល់ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នា និង មិនរើសអើងនៅក្នុងក្រមខណ្ឌពេលវេលាមួយ ដ៏សមហេតុផល[៦]។

ការឆ្លើយតបអាចជា:

- ការបំពេញសេវាកម្មជូនប្រជាពលរដ្ឋតាមការស្នើសុំ

[៥] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃចំណុចគណនេយ្យភាពទំព័រ១៧
[៦] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃចំណុចការឆ្លើយតបទំព័រទី១៨

- ដំណោះស្រាយដែលស្តែងឡើងជាសកម្មភាពដើម្បីដោះស្រាយបញ្ហា ឬ ការលំបាកនានា
- ការឆ្លើយបំភ្លឺអំពីមូលហេតុ ដែលមិនអាចឈានដល់ការធ្វើសកម្មភាពដើម្បី ដោះស្រាយបញ្ហា ឬ ការលំបាកទាំងនោះបាន
- សំណើសុំអន្តរាគមន៍ពីស្ថាប័ន អង្គភាពមានសមត្ថកិច្ច ដើម្បីជួយដោះស្រាយបញ្ហា ឬការលំបាកទាំងនោះព្រមទាំងជំរាបអំពីសំណើសុំអន្តរាគមន៍នេះដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងបញ្ហា ឬ ការលំបាកទាំងនោះ ។

**ទី៩.ចក្ខុវិស័យជាយុទ្ធសាស្ត្រ** មានន័យថា សម្រាប់ស្ថាប័នសាធារណៈ ឬ អង្គភាពណាមួយ ជាពិសេស គឺសំដៅដល់អ្នកដឹកនាំផ្ទាល់តែម្តង ត្រូវមានទស្សនៈវិស័យវែងឆ្ងាយ ទូលំទូលាយ ល្អិតល្អន់ក្នុងការគ្រប់គ្រង និង ប្រើប្រាស់ធនធានរបស់ខ្លួន ដើម្បីធានាបាននូវភាពយូរអង្វែង ។ ជាងនេះទៅទៀត អ្នកដឹកនាំត្រូវតែធ្វើការស្វែងយល់ឲ្យបានច្បាស់ពីគ្រប់ទិដ្ឋភាពនានារួមមាន ផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ និង សង្គម ដែលពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ ។

គួរកត់សម្គាល់ នៅក្នុងក្របខណ្ឌខ្លះ គឺអភិបាលកិច្ចល្អត្រូវបានលើកឡើតតែ ៨ ចំណុចតែប៉ុណ្ណោះ ។ ជាសរុបនៅក្នុងជំពូកទី១ នេះគឺគ្រាន់តែធ្វើការលើកបង្ហាញ ពីគ្រប់ទិដ្ឋភាពនានាជុំវិញទ្រឹស្តីអភិបាលកិច្ចល្អ ហើយក៏ជាការ ធ្វើការណែនាំឲ្យបានស្គាល់ ពីឃុំតានី ដែលជាតួឯកនៅក្នុងប្រធានបទ នៃរបាយការណ៍ស្រាវជ្រាវឯកសារនេះ។

# ជំពូកទី២

# សកម្មភាពការងាររបស់ឃុំ

## ២.១. តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធរបស់ឃុំ

ការស្វែងយល់អំពីអភិបាលកិច្ចល្អរបស់ស្ថាប័ន ឬ អង្គភាពមួយ បានធ្វើឲ្យប្រជាពលរដ្ឋយល់ដឹង និង បង្ហាញឲ្យឃើញពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើឲ្យមានអភិបាលកិច្ចល្អតាមរយៈការតាមដានការប្រតិបត្តិការការងាររបស់ស្ថាប័ន ឬ អង្គភាពនោះ ។ បច្ចុប្បន្ន រដ្ឋបាលឃុំមានតួនាទីជំរុញ និង គាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំរបស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និង គោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ[១០]។

### ២.១.១. តួនាទី ភារកិច្ច

នៅក្នុងកិច្ចដំណើរការនៃការប្រព្រឹត្តទៅរបស់រដ្ឋបាលឃុំតានី ត្រូវមានតួនាទី និង ភារកិច្ចក្នុងការបម្រើផលប្រយោជន៍ជូនជាតិ និង ប្រជាពលរដ្ឋ ។

ឃុំតានី មានតួនាទីពីរប្រភេទគឺ៖

- តួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ និង ប្រជាពលរដ្ឋក្នុងឃុំ របស់ខ្លួន។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬ ការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ[១១]។

នៅក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន ឃុំ មានភារកិច្ចៈ

ក្នុងភារកិច្ចតំណាងឲ្យប្រជាពលរដ្ឋ៖

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និង មើលការខុសត្រូវឲ្យកិច្ចការទាំងអស់នោះដំណើរការបានល្អ
- លើកទឹកចិត្តឲ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជម្រុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និង លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

[១០] មាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[១១] មាត្រា៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បី ឲ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំផុសប្រជាពលរដ្ឋ ឲ្យបំពេញកាតព្វកិច្ច ដែលជាផលប្រយោជន៍រួមរបស់ឃុំ
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ[១២]។

នៅក្នុងភារកិច្ចជាភ្នាក់ងារតំណាងឲ្យរដ្ឋ ឃុំតានី មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋានពាក់ព័ន្ធ។

ក្នុងឋានៈតំណាងឲ្យរដ្ឋ៖

- ជាអ្នកទទួលខុសត្រូវចំពោះការដឹកនាំរដ្ឋបាលឃុំ និង នយោបាយក្នុងឃុំ
- គ្រប់គ្រង និង ធ្វើស្ថិតិប្រជាពលរដ្ឋ
- គ្រប់គ្រងបញ្ជីរាយនាមប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត និង ស្ថិតិជនបរទេស
- ដឹកនាំនគរបាលប៉ុស្តិ៍រដ្ឋបាល
- ជាមន្ត្រីអត្រានុកូលដ្ឋាន«ក៣»
- សហការ និង ជួយដល់មន្ត្រីពន្ធដារ ដែលមានបេសកកម្មប្រមូលពន្ធដារ នៅក្នុងឃុំរបស់ខ្លួន
- សហការជាមួយឃុំ ដែលមាននៅជិតព្រំប្រទល់គ្នា ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ និង ការបង្ការ បង្ក្រាបបទល្មើសនានា។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ ដោយភ្ជាប់ជាមួយនូវការបង្កើតសមត្ថភាព និង ផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សម្រាប់អនុវត្ត។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ ប៉ុណ្ណោះ[១៣]។

ឃុំ មានអំណាចបញ្ញត្តិ និង អំណាចប្រតិបត្តិ។

អំណាចបញ្ញត្តិរបស់ឃុំ ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌ តួនាទី មុខងារ និង អំណាចរបស់ខ្លួន។ ដីកាឃុំ ត្រូវធ្វើឡើងតាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាឃុំ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ។

រដ្ឋបាលឃុំ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និង ជាបន្ទាន់ក្នុងឃុំ របស់ខ្លួននូវដីកាដែលបានសម្រេចរួចហើយ[១៤]។

---

[១២] មាត្រា៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[១៣] មាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

**២.១.២. រចនាសម្ព័ន្ធរបស់ឃុំតានី**

រដ្ឋបាលឃុំ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ ។

ក្រុមប្រឹក្សាឃុំ ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់[១៥]។

មានដូចជា៖

- **ក្រុមប្រឹក្សាឃុំ តានី**
- **មេឃុំ តានី**
- **ជំទប់ទី១ ឃុំតានី**
- **ជំទប់ទី២ ឃុំតានី**
- **ស្មៀនឃុំ**
- **មេភូមិ**
- **គណៈកម្មាធិការនិងជំនួយការនានា**

ហើយនៅក្នុងចង្កោមរចនាសម្ព័ន្ធរបស់ឃុំតានីត្រូវមាន តួនាទី ភារកិច្ច និង ការទទួលខុសត្រូវផ្សេងៗគ្នាទៅតាមមុខងារ ដោយស្ថិតក្រោមឱវាទរបស់មេឃុំ ។ យើងនឹងធ្វើការបង្ហាញអំពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និង សមាជិកនៃឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ។

**២.១.២.១.ក្រុមប្រឹក្សាឃុំតានី**

រដ្ឋបាលឃុំ ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ ។ ក្រុមប្រឹក្សាឃុំ មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រ និង ភូមិសាស្ត្ររបស់ខ្លួន[១៦]។

ក្រុមប្រឹក្សាឃុំតានីមានសមាជិកចំនួន ៩នាក់ ។ ក្រុមប្រឹក្សាឃុំតានី ត្រូវមានប្រធានម្នាក់ហៅថា ប្រធានក្រុមប្រឹក្សាឃុំ ។ ក្រុមប្រឹក្សាឃុំតានី មានអាណត្តិ ៥ឆ្នាំ ដែលត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ ស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ។

**២.១.២.២.មេឃុំ តានី**

មេឃុំ ដើរតួនាទីជាប្រធានក្រុមប្រឹក្សាឃុំផង និង ជាមេឃុំផង ។ នៅពេលមានការប្រជុំក្រុមប្រឹក្សាឃុំទាំង ៩នាក់ មេឃុំដើរតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ ។

ប្រធានក្រុមប្រឹក្សាឃុំ មានភារកិច្ច៖

---

[១៤] មាត្រា៤៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[១៥] មាត្រា២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[១៦] មាត្រា១២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ របស់ខ្លួន
- ធានាឲ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ យ៉ាងតិចឲ្យបានមួយដងក្នុងមួយខែ
- ធានាឲ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាន និង បទបញ្ញាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ និង បទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់ពីការ គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- រក្សារបៀបរៀបរយ និង សណ្តាប់ធ្នាប់ក្នុងពេលប្រជុំ[១៧]។

ក្រុមប្រឹក្សាឃុំ ត្រូវធ្វើការប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ[១៨]។

ប៉ន្តែក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចធ្វើការប្រជុំពិសេស ដោយការប្រជុំពិសេសនេះប្រារព្ធឡើងក្នុងអំឡុងពេលបីថ្ងៃ បន្ទាប់ពីប្រធានក្រុមប្រឹក្សាឃុំ ឬ សមាជិកចំនួន មួយភាគបី យ៉ាងតិចនៃសមាជិកក្រុមប្រឹក្សាទាំងអស់ ស្នើសុំឲ្យរៀបចំកិច្ចប្រជុំពិសេសនេះ ។ ការសម្រេច ឬ ការស្នើសុំឲ្យមានការប្រជុំពិសេសត្រូវបញ្ជាក់ពីមូលហេតុឲ្យបានសមស្រប[១៩]។

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ និង គណៈកម្មាធិការជំនួយការត្រូវធ្វើជាសាធារណៈ ។

ប៉ុន្តែ នៅពេលដែលមានការប្រជុំលើកឡើងពីគម្រោងសាងសង់អ្វីមួយ (ឧទាហរណ៍ៈ ការសាងសង់ផ្លូវ) ប្រធានក្រុមប្រឹក្សាឃុំធ្វើការកោះហៅសមាជិកក្រុមប្រឹក្សាឃុំមកប្រជុំ ហើយនៅពេលធ្វើការប្រជុំរួចហើយ មេឃុំ បំពេញតួនាទីភារកិច្ចដូចខាងក្រោម[២០]៖

- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ
- អនុវត្តបទប្បញ្ញត្តិ និង គោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ របស់ខ្លួនយ៉ាងតិចឲ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗ និង ជួយដល់ក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំផែនការហិរញ្ញវត្ថុ និង ការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ របស់ខ្លួនប្រគល់ឲ្យ។

---

[១៧] មាត្រា១៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[១៨] មាត្រា២១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[១៩] ប្រការ១ នៃប្រកាសលេខ១៦០៨ ប្រ.ក ស្តីពី ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំតានីស្រុកអង្គរជ័យ ខេត្តកំពត

[២០] មាត្រា៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

មេឃុំ មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និង ជួយកិច្ចការនានាតាមការចាំបាច់។

គណៈកម្មាធិការដែលមេឃុំចាត់តាំងអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ ឲ្យធ្វើជាប្រធានក៏បាន ឬ អាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំរបស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឲ្យធ្វើជាប្រធានក៏បាន។

### ២.១.២.៣.ជំទប់ទី១ ឃុំតានី

ជំទប់ទី១ គឺជាជំនួយការរបស់មេឃុំ ទទួលជួយមេឃុំ លើកិច្ចការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### ២.១.២.៤.ជំទប់ទី២ ឃុំតានី

ជំទប់ទី២ គឺជាជំនួយការរបស់មេឃុំ ទទួលជួយមេឃុំ លើកិច្ចការ រដ្ឋបាល សង្គមកិច្ច សេវាសាធារណៈ និង សណ្តាប់ធ្នាប់សាធារណៈ ។

### ២.១.២.៥.ស្មៀនឃុំ

នៅក្នុងក្របខណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃឃុំ ត្រូវមានបុគ្គលិកមួយរូបធ្វើជាស្មៀនឃុំ។ ស្មៀនឃុំ តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ និង ធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ[២១]។

ស្មៀនឃុំ ត្រូវរក្សាទុកឯកសារចម្លងនៃរបៀបវារៈកិច្ចប្រជុំ ឯកសារ កំណត់ហេតុ និង មាតិកាសំខាន់ៗនៃកិច្ចប្រជុំនៅក្នុងសាលាឃុំ ដើម្បីឲ្យសាធារណជនពិនិត្យមើល។

ស្មៀនឃុំ និង បុគ្គលិកផ្សេងទៀតដែលតែងតាំងដោយក្រុមប្រឹក្សាឃុំ មានសិទ្ធិចូលរួម និង អាចបញ្ចេញមតិយោបល់ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ទៅតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សា ប៉ុន្តែ ពុំមានសិទ្ធិបោះឆ្នោតឡើយ។

### ២.១.២.៦.មេភូមិ

ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ ក្រុមប្រឹក្សាឃុំ នីមួយៗត្រូវរៀបចំជ្រើសរើសឲ្យមានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗចំណុះឃុំ របស់ខ្លួន ។ ហើយមេភូមិត្រូវរៀបចំចាត់តាំងឲ្យមានអនុប្រធានមួយរូប និង សមាជិកមួយរូបជាជំនួយការ។

មេភូមិមានភារកិច្ចៈ

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ ឬ មេឃុំ ប្រគល់ឲ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចក្នុងភូមិ

[២១] មាត្រា២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងភូមិខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ មេឃុំ ដើម្បីចាត់ចែង និង សម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន[២២]។

អនុប្រធានភូមិ និង សមាជិកភូមិ ជាជំនួយការរបស់មេភូមិក្នុងការអនុវត្តភារកិច្ចដែលមេភូមិប្រគល់ឲ្យ និង ជំនួសមេភូមិទៅតាមឋានានុក្រម នៅពេលដែលមេភូមិអវត្តមាន។

## ២.១.២.៧.គណកម្មាធិការនិងជំនួយការនានា

នៅក្នុងឃុំតានីនេះ មេឃុំ បានចាត់តាំងឲ្យមានគណកម្មាធិការនានាចំនួន០៤ គឺ៖

- គណកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ
- គណកម្មាធិការកសារផែនការនិងថវិកា
- គណកម្មាធិកាលទ្ធកម្ម
- គណកម្មាធិកាដោះស្រាយវិវាទ ។

គណកម្មាធិការទាំងអស់នេះមានភារកិច្ច ដូចជា៖

គណៈកម្មាធិការថ្នាក់ឃុំមានភារកិច្ច៖

- ជួយអ្នកសម្របសម្រួលតំណាងភូមិ និង ប្រធានភូមិ ឬ អនុប្រធានភូមិ ដើម្បីជ្រើសរើស បេក្ខជន សមាជិក ក្រុមតំណាងភូមិ។
- ជួយសម្របសម្រួល និង រៀបចំផែនការសកម្មភាពដល់ក្រុមតំណាងភូមិ។
- ជួយសម្របសម្រួលការងារក្រុម សម្របសម្រួលស្រុកក្នុងការរៀបចំវគ្គបណ្តុះបណ្តាល តាមដានការងាររបស់ក្រុមតំណាងភូមិ ផ្តល់ព័ត៌មានការបែងចែក សម្ភារៈ និង ថវិកា។
- ផ្តល់ការណែនាំដល់ក្រុមតំណាងភូមិអំពីការអនុវត្តនីតិវិធី និង ជួយដោះស្រាយបញ្ហាដែលកើតមាន។
- ផ្តល់ការណែនាំ និង ការគាំទ្រសំរាប់ការរៀបចំកិច្ចប្រជុំលើកដំបូង។
- ត្រួតពិនិត្យបន្ថែមថា តើគ្រួសារណាដែលត្រូវបញ្ចូល និង គ្រួសារណាដែលមិនត្រូវបញ្ចូលក្នុងបញ្ជីគ្រួសារក្រីក្រ។
- ត្រួតពិនិត្យ ការដាក់ពិន្ទុ និង បូកសរុបពិន្ទុ ក្រោយពីក្រុមតំណាងភូមិសម្ភាសន៍រួច។

[២២] មាត្រា៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- រៀបចំ និង ចូលរួមប្រជុំពិនិត្យបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រឡើងវិញនៅថ្នាក់ឃុំ។
- បិទផ្សាយបញ្ជីព្រាងគ្រួសារលើកដំបូង និង បញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ
- តាមដានកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិ។
- រៀបចំ និង ចូលរួមប្រជុំអនុម័តបញ្ជីគ្រួសារក្រីក្រចុងក្រោយ។
- ពិចារណាឡើងវិញ និង ត្រួតពិនិត្យនីតិវិធីដែលក្រុមតំណាងភូមិអនុវត្ត បើសិនជាក្រុមប្រឹក្សាឃុំតម្រូវឲ្យធ្វើ។
- តាមដានការចែកបណ្ណសមធម៌ និង ធ្វើរបាយការណ៍ស្តីពីការចែកបណ្ណសមធម៌ទៅមន្ទីរផែនការខេត្ត។

សមាជិកក្រុមតំណាងគណៈកម្មាធិការដែលជាអ្នកសម្របសម្រួលក្រុមតំណាងភូមិមានភារកិច្ចៈ

- សម្របសម្រួលការជ្រើសរើសបេក្ខជនក្រុមតំណាងភូមិ ក្នុងភូមិដែលខ្លួនទទួលខុសត្រូវ (សហការជាមួយប្រធាន ឬ អនុប្រធានភូមិដែលជាសមាជិកក្រុមតំណាងថ្នាក់ឃុំ ដែលទទួលខុសត្រូវភូមិនោះ)។
- សមាជិកក្រុមតំណាងគណៈកម្មាធិការមួយចំនួន ដែលជាអ្នកសម្របសម្រួលក្រុមតំណាងភូមិអាច និង ក្លាយជាអ្នកបណ្តុះបណ្តាលដល់ក្រុមតំណាងភូមិ។
- សម្របសម្រួល និង ត្រួតពិនិត្យការចងក្រងបញ្ជីគ្រួសារក្នុងភូមិសម្រាប់ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។
- ត្រួតពិនិត្យការជ្រើសរើសគ្រួសារដែលត្រូវសម្ភាសន៍ និង ផ្តល់ការណែនាំដល់សមាជិកក្រុមតំណាងភូមិក្នុងដំណើរការសម្ភាសន៍តាមគ្រួសារ។
- សម្របសម្រួលក្រុមតំណាងភូមិក្នុងការត្រួតពិនិត្យ ការដាក់ពិន្ទុ ការបូកពិន្ទុ ការរៀបចំបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រ និង ការពិភាក្សាដើម្បីផ្លាស់ប្តូរចំណាត់ថ្នាក់គ្រួសារមួយចំនួនក្នុងបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រ។
- ចូលរួមប្រជុំត្រួតពិនិត្យបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រឡើងវិញនៅថ្នាក់ឃុំ។
- សហការជាមួយប្រធាន ឬ អនុប្រធានភូមិដែលជាសមាជិកក្រុមតំណាងភូមិ ដើម្បីសម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិ។
- សម្របសម្រួលការពិចារណាលើមតិជំទាស់ និង សំណូមពររបស់អ្នកភូមិដើម្បីផ្លាស់ប្តូរចំណាត់ថ្នាក់គ្រួសារក្រីក្រ។

## ២.២. ភូមិឃុំមានសុវត្ថិភាព

ដើម្បីឲ្យភូមិឃុំ មានសុវត្ថិភាព យើងត្រូវអនុវត្តគោលនយោបាយ ៩ចំណុចដូចខាងក្រោម:

- គ្មានសកម្មភាព លួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការផលិត ការចែកចាយ និង ប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រីនិងកុមារ និង អំពើហឹង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និង បទល្មើសគ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- មានវិធានការទប់ស្កាត់ គ្រប់គ្រង និង ឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយ ប្រសិទ្ធភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់

ការអនុវត្តបាននូវវិធានការគោលនយោបាយភូមិឃុំ មានសុវត្ថិភាពទាំង ៩ ចំណុចនេះ ជាហេតុដែលនាំឲ្យភូមិ ឃុំ មានការអភិវឌ្ឍ ប្រកបដោយ សន្តិសុខ សណ្តាប់ធ្នាប់ និង មានរបៀបរៀបរយ។ ការបង្កើនការយកចិត្តទុកដាក់ទៅលើសន្តិសុខនៅក្នុងមូលដ្ឋានភូមិ ឃុំ បង្ក្រាប និង ទប់ស្កាត់រាល់ អំពើដែលនាំឲ្យមានភាពអសន្តិសុខទាំងឡាយ ជាករណីកិច្ចរបស់ក្រុមប្រឹក្សាឃុំ ធ្វើយ៉ាងណាគោរព និង អនុវត្តគោលនយោបាយនេះឲ្យមានដំណើរការល្អតាមរយៈនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំប្រកបដោយប្រសិទ្ធភាព ឆ្លើយតប ទៅនឹងការព្រួយបារម្ភ និង តម្រូវការរបស់ប្រជាពលរដ្ឋ ។

ទោះជាមានការខិតខំប្រឹងប្រែងអនុវត្ត តាមគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពបានល្អយ៉ាងនេះក្តីក៏ការអនុវត្តនេះ នៅតែមានចន្លោះប្រហោងខ្វះខាតមិនទាន់គ្រប់ជ្រុងជ្រោយដែលជាហេតុនាំឲ្យមានបទល្មើសនៅតែកើតមានឡើងជារើយៗ ។

## ២.៣. ប្រជាការពារ

ភូមិឃុំមានសុវត្ថិភាពបានចុះប្រជុំតាមភូមិទាំង០៧ ក្នុងឃុំ សហការជាមួយកំលាំងប៉ុស្តិ៍រដ្ឋបាល និង កំលាំងមកពីខេត្ត ចុះបង្កើតប្រជាការពារតាមភូមិ ដោយមួយភូមិបង្កើតប្រជាការពារចងក្រងជាពីរក្រុម ។

ការបង្កើតឲ្យមានប្រជាការពារ គឺដើម្បីធានាឲ្យភូមិឃុំមានសុវត្ថិភាព លុបបំបាត់រាល់សកម្មភាពទាំងឡាយណាដែលនាំឲ្យប្រជាពលរដ្ឋមានការព្រួយបារម្ភ និង មានភាពចលាចលក្នុង

សង្គម ។ ហើយឃុំបានចាត់វិធាការក្នុងការការពារ និង ជួយដល់ប្រជាពលរដ្ឋ ដោយចាត់កំលាំងនគរបាល ប៉ុស្តិ៍រដ្ឋបាលរបស់ឃុំ ចុះទៅជួយយាមម៉ូតូក្នុងកម្មពិធីផ្សេងៗរបស់ប្រជាពលរដ្ឋ ដែលប្រជាពលរដ្ឋបានសុំអនុញ្ញាតពីឃុំ ដោយពុំគិតពីកម្រៃតបស្នង និង វិធានការផ្សេងៗទៀតដូចជាដាក់កម្លាំងយាមល្បាតនៅពេលយប់តាមភូមិ តាមផ្លូវតូច ផ្លូវធំ តាមច្រកល្ហកផ្សេងៗ ដើម្បីត្រួតពិនិត្យ និង ទប់ស្កាត់សកម្មភាពក្រុមក្មេងទំនើងដើរលេងយប់ អំពើលួច ឆក់ ប្លន់ សកម្មភាពចែកចាយគ្រឿងញៀន ក្មេងប្រើប្រាស់គ្រឿងញៀន និង សកម្មភាពផ្សេងៗទៀតដែលនាំឲ្យមានភាពចលាចលដល់សង្គម និង ដល់ការអភិវឌ្ឍមូលដ្ឋានក្នុងឃុំតានី ស្រុកអង្គរជ័យទាំងមូល។

### ២.៤. ការបង្កើតផែនការអភិវឌ្ឍន៍ឃុំ

ការបង្កើតផែនការអភិវឌ្ឍន៍ របស់ឃុំត្រូវបានបង្កើតឡើងដោយត្រូវគោរព និង ស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ ជាពិសេស គឺគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់ឃុំ។ ដើម្បីធ្វើឲ្យមានភាពល្អប្រសើរនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ ក្រុមប្រឹក្សាឃុំ ត្រូវចាត់វិធានការដូចតទៅ:

- វាយតម្លៃអំពីកម្រិតអត្ថិភាពនៃការអភិវឌ្ឍន៍ និង សកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំរបស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ និង កំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំមាន និង ធនធានដែលទទួលបាន
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវា និង ការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ
- ផ្តល់សេវា និង ការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យតាមដាន និង វាយតម្លៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតម្លៃកម្រិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំរបស់ខ្លួន។

ក្រុមប្រឹក្សាឃុំ ត្រូវដឹកនាំការងារឲ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ របស់ខ្លួន។

ផែនការអភិវឌ្ឍន៍ឃុំ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិ និង សំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយ ហើយក៏ត្រូវកំណត់ផងដែរនូវវិធីសាស្រ្ត និង មធ្យោបាយនានាដើម្បីបង្កលទ្ធភាពឲ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល[២៣] ។

[២៣] មាត្រា៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ២.២.១. សកម្មភាពប្រចាំឆ្នាំ២០១៥

សកម្មភាពប្រចាំឆ្នាំ២០១៥ ជាសកម្មភាពដែលមានលក្ខណៈធំទូលាយ និង មានប្រតិទិនការងារច្បាប់លាស់ ។ ហើយសកម្មភាពប្រចាំឆ្នាំ២០១៥ គឺត្រូវគោរព និង ស្របជាមួយផែនការសកម្មភាពរបស់ឃុំ ដែលរួមមានដូចជា: ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកធនធានធម្មជាតិនិងបរិស្ថាន ផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ និង ផ្នែកយេនឌ័រ ។

#### ក. ផ្នែកសេដ្ឋកិច្ច

នៅក្នុងផ្នែកសេដ្ឋកិច្ចនេះ ឃុំផ្តោតសំខាន់ទៅលើកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធផ្លូវលំជនបទការងារធនធានទឹក ឧស្សាហកម្មនិងថាមពល ដែលជាសកម្មភាពសំខាន់ៗក្នុងការអភិវឌ្ឍភូមិ ទាំង០៧ ក្នុងឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ពីមួយឆ្នាំទៅមួយឆ្នាំ ក្រុមប្រឹក្សាឃុំបានយកចិត្តទុកដាក់យ៉ាងមុតមាំក្នុងការស្វះស្វែងរកមធ្យោបាយ ដើម្បីធ្វើការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋទាំង០៧ ភូមិ ទូទាំងឃុំតានី ។ យ៉ាងណាមិញក្រុមប្រឹក្សា ឃុំបានធ្វើការណែនាំ ជម្រុញ លើកទឹកចិត្ត ដល់ប្រជាពលរដ្ឋឲ្យធ្វើការយកចិត្តទុកដាក់ទៅលើការធ្វើស្រែប្រាំង ការផ្លាស់ពូជដំណាំ ការចិញ្ចឹមសត្វតាមបែបបច្ចេកទេស ជួយថែរក្សា និង ស្តារប្រឡាយដែលជាមេប្រភពទឹកដើម្បីទុកទឹកស្រោចស្រពដំណាំ។ ប៉ុន្តែ មានតែភូមិពីរ ប៉ុណ្ណោះក្នុងចំណោមភូមិទាំងប្រាំពីរទូទាំងឃុំតានី ដែលមានមេប្រឡាទឹកងាយស្រួលដល់ការរក្សាទឹកទុក គឺមានភូមិឫស្សី និងភូមិតាកុក ។

សព្វថ្ងៃនេះ ប្រជាពលរដ្ឋភាគច្រើនក្នុងភូមិទាំង០៧ ទូទាំងឃុំ គឺទទួលបានការប្រើប្រាស់ភ្លើងអគ្គីសនី ហើយ គ្រួសារមួយចំនួនពុំទាន់បានប្រើប្រាស់។

#### ខ. ផ្នែកសង្គមកិច្ច

ដោយប្រជាពលរដ្ឋមានជំនឿរទៅលើវិស័យសុខាភិបាល វិស័យអប់រំ ជាហេតុដែលនាំឲ្យផ្នែកសង្គមកិច្ចមានដំណើរការល្អ ។ ប្រជាពលរដ្ឋភាគច្រើនបានយល់ដឹងពីអត្ថប្រយោជន៍ និង តម្លៃនៃការសិក្សាហើយពួកគាត់ បានបញ្ជូនកូនៗរបស់គាត់ឲ្យទៅសិក្សាក្រេបយកចំណេះដឹងដើម្បីអនាគតដ៏ភ្លឺស្វាងរបស់ពួកគេ ។ នេះជាមូលហេតុដែលក្រុមប្រឹក្សាឃុំតានី បានយកចិត្តទុកដាក់ ក្នុងការពន្យល់ណែនាំពីគុណសម្បត្តិនៃការសិក្សា និង ធ្វើការផ្សព្វផ្សាយពីចំណេះដឹងផ្សេងៗ ដូចជាសុខភាពអនាម័យ សេវាកម្មសុខាភិបាល បរិស្ថានស្អាត ជូនដល់ប្រជាពលរដ្ឋទាំង០៧ ភូមិទូទាំងឃុំតានីឲ្យមាននូវចំណេះដឹង និង ចំណេះធ្វើ ដែលអាចដោះស្រាយបញ្ហាបានខ្លះនៅក្នុងសង្គមថែមទាំងមានទំនួលខុសត្រូវខ្ពស់ក្នុងសង្គម។

បច្ចុប្បន្នប្រជាពលរដ្ឋក្នុងឃុំតានី ទទួលបានការយល់ដឹងអំពីអត្ថប្រយោជន៍ពីការ ទៅត្រួតពិនិត្យសុខភាពនៅមណ្ឌលសុខភាព ហើយមានការកាត់បន្ថយអត្រាការស្លាប់របស់ មាតា និង ទារក នៅពេលឆ្លងទន្លេ។

## គ. ផ្នែកធនធានធម្មជាតិ និងបរិស្ថាន

ដោយហេតុថា ឃុំតានី គឺជាឃុំមួយដែលស្ថិតនៅក្នុងតំបន់មួយដែលមានកូនភ្នំ និង បឹងធម្មជាតិ នៅពេលដែលមានគម្រោងផែនការកសាងអ្វីមួយ ជាដំបូងគេផ្តោតសំខាន់ទៅលើបរិស្ថាន និងធនធានធម្មជាតិ ធ្វើយ៉ាងណាធានាកុំឲ្យមានផលប៉ះពាល់ ដែលនាំឲ្យមានការខូចខាត និង បាត់បង់សោភណ្ឌភាពបរិស្ថាន ។ ប៉ុន្តែជាកត់សម្គាល់ នូវរាល់សកម្មភាពនៃការអភិវឌ្ឍ ឬ សកម្មភាពនៃគម្រោងផែនការកសាងដូចជា កសាងផ្លូវ ជាដើម ពុំដែលមានបញ្ហាអ្វីចោទឡើងទេ ប៉ុន្តែទោះជាសកម្មភាពកសាងផ្លូវពុំបណ្តាលឲ្យមានផលប៉ះពាល់ដល់បរិស្ថានដ៏ដោយ ក៏គេសង្កេតឃើញថានូវមានបញ្ហាមួយចំនួនដែលនាំឲ្យមានផលប៉ះពាល់ដល់បរិស្ថាន និង ធនធានធម្មជាតិ នោះគឺគ្រោះធម្មជាតិ ។

## ឃ.ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ

ការបង្កើននូវការយកចិត្តទុកដាក់ពីគ្រប់មជ្ឈដ្ឋាន មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ប្រជាជន គ្រប់ស្រទាប់ ចូលរួមក្នុងការផ្តល់សេវា និង ទទួលសេវា នៅសាលាឃុំតានី ឲ្យមានតម្លាភាព និង ចូលរួមបំបាត់ការយកសេវាខុសច្បាប់ និង ចូលរួមលុបបំបាត់អំពើពុករលួយ ដោយផ្អែកតាមកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

កំណត់បាននូវមុខសញ្ញា និង ទីកន្លែង ពេលវេលា ដែលត្រូវផ្តល់សេវា និង បង់ប្រាក់ថ្លៃសេវា ។ ចំពោះការផ្តល់សេវា ការកំណត់តម្លៃ និង ទីកន្លែងបង់ថ្លៃសេវា ស្ថិតនៅក្នុងដែន សមត្ថកិច្ចរបស់សាលាឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ។ បង្កើនការយកចិត្តទុកដាក់លើ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ដោយកំណត់បាននូវតម្លៃ ពេលវេលា ទីកន្លែង ច្បាស់លាស់ និងរៀបចំយន្តការច្បាស់លាស់សម្រាប់ការអនុវត្ត និង មានវិធានការយ៉ាងម៉ត់ចត់បំផុត ចំពោះការអនុវត្តការផ្តល់សេវាជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ។ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តន៍ ត្រូវចាត់តាំងមន្ត្រីដែល មានសមត្ថភាពទទួលភារកិច្ចដើម្បីគ្រប់គ្រងការអនុវត្តន៍ការផ្តល់សេវានៅសាលាឃុំតានីដោយផ្អែក តាមការណែនាំរបស់ក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖

- ជម្រុញការផ្តល់សេវាសាធារណៈគ្រប់ប្រភេទជូនប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលា
- ទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូលឲ្យបានល្អ និង យកទៅបង់នៅរតនាគារតាមការកំណត់
- ធ្វើរបាយការណ៍រាយការណ៍ជូនក្រុមប្រឹក្សាឃុំ និង គ្រប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ។

**ខ. ផ្នែកយេនឌ័រ**

ក្នុងផ្នែកយេនឌ័រនេះក្រុមប្រឹក្សាឃុំ បានបង្កើតឲ្យមានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ដែលស្របទៅនឹងបទបញ្ញាផ្ទៃក្នុង របស់ឃុំតានីស្រុកអង្គរជ័យ ខេត្តកំពត ក្រុមប្រឹក្សាឃុំ បានតែងតាំងសមាជិកក្រុមប្រឹក្សាឃុំ ម្នាក់ជានារី ដែលមានភារកិច្ចទទួលបន្ទុកផ្នែកកិច្ចការនារី និងកុមារ ដែលត្រូវយកចិត្តទុកដាក់ ទៅលើបញ្ហាមួយចំនួនដូចជា អំពើហឹង្សាក្នុងគ្រួសារ ស្ត្រីមេម៉ាយ កុមារបោះបង់ការសិក្សា ជនពិការ អ្នកផ្ទុកមេរោគអេដស៍ និង អ្នកឆ្លងជំងឺអេដស៍ជាដើម។

# ជំពូកទី៣

# លទ្ធផលការងារ បញ្ហាប្រឈម និងទិសដៅសកម្មភាពឆ្នាំ២០១៦

## ៣.១. លទ្ធផលការងាររបស់ឃុំ

ការអនុវត្តតាមទិសដៅសកម្មភាព ក្នុងការអភិវឌ្ឍក្នុងមូលដ្ឋានភូមិ ឃុំរបស់ខ្លួនកន្លងមក និង មកដល់បច្ចុប្បន្ន បានធ្វើឲ្យមានលក្ខណៈល្អប្រសើរលើគ្រប់ផ្នែកទាំងអស់។ គួរបញ្ជាក់ផងដែរថា ឃុំគឺមានរបាយការណ៍បូកសរុបប្រចាំឆ្នាំ និង លទ្ធផលនៃកិច្ចប្រតិបត្តិការការងារប្រចាំឆ្នាំរបស់ខ្លួនព្រមទាំងមានការអនុវត្តន៍គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និង ប្រជាការពាររបស់ឃុំតានីផ្ទាល់បន្ថែមទៀតផង ។

### ៣.១.១. សភាពការណ៍រួម

ក្រុមប្រឹក្សាឃុំតានី បានខិតខំធ្វើការឆ្លើយតបបានយ៉ាងល្អប្រសើរ និង ទាន់ពេលវេលាទៅលើការអភិវឌ្ឍគ្រប់ផ្នែកដូចជា: ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការលើកកំពស់វិស័យកសិកម្ម (បង្កើនទិន្នផលស្រូវ) វិស័យឧស្សាហាកម្ម (ការបង្កើតផលិតចំណីសត្វតាមបច្ចេកទេសត្រឹមត្រូវ) សុខភាពអនាម័យ អប់រំសុខាភិបាល ធនធានធម្មជាតិ បរិស្ថាន សេវាកម្មរដ្ឋបាល និង យេនឌ័រ ជាយុទ្ធសាស្ត្រដែលឃុំបានប្រកាន់យកដើម្បីអភិវឌ្ឍន៍ក្នុងមូលដ្ឋាន ។

### ៣.១.២. លទ្ធផលនៃកិច្ចប្រតិបត្តិការតាមផ្នែកនីមួយៗ

តាមរយៈលទ្ធផលការងារដែលឃុំសម្រេចបាន គឺរំលេចឲ្យឃើញនូវកិច្ចខិតខំប្រឹងប្រែងរបស់ឃុំ ក្នុងការរកដំណោះស្រាយ និងរៀបចំផែនការអភិវឌ្ឍន៍នៅតាមបណ្តាភូមិនានាទាំង០៧ភូមិក្នុងឃុំ ជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរដែលពាក់ព័ន្ធក្នុងការអនុវត្តផែនការសកម្មភាព និង ទិសដៅការងាររបស់ឃុំ ។ ជាពិសេសមេឃុំ បានប្រតិបត្តិការងាររបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួននូវតួនាទី ភារកិច្ចជាមេដឹកនាំ និង ពង្រឹងសមត្ថភាព លើកកម្ពស់ក្រមសីលធម៌របស់ខ្លួន ដើម្បីទទួលបានការគាំទ្រពីប្រជាពលរដ្ឋ និង សមាជិកឃុំនៅក្នុង ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត។

ដោយយោងទៅលើការវិភាគក្នុងព័ត៌មានស្ថានភាពឃុំ សូចនាករតាមវិស័យ ផែនទីរដ្ឋបាល សៀវភៅទិន្នន័យភូមិ ឃុំ សូចនាករគោលដៅអភិវឌ្ឍន៍សហសវត្សន៍កម្ពុជា របាយការណ៍ផែនការអភិវឌ្ឍន៍ឃុំអាណត្តិមុន ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចលើកទី២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានបង្ហាញឲ្យឃើញថា ឃុំបានទទួលលទ្ធផលការងារល្អ ក្នុងនោះមានដូចជា៖

#### ក. លទ្ធផលនៃកិច្ចប្រតិបត្តិការផ្នែកសេដ្ឋកិច្ច

##### ក.១. កសិកម្ម

ផ្អែកលើស្ថានភាពភូមិសាស្ត្ររបស់ឃុំ តានី ការងារធ្វើស្រែរបស់ប្រជាពលរដ្ឋ ក្នុងឆ្នាំកន្លងមកលើផ្ទៃដីសម្រាប់ស្រូវវស្សាចំនួន ១.៦៤៦ ហិចតា បានទទួលទិន្នផលជាមធ្យមពី ២.៥០តោន

ក្នុងមួយហិចតា ។ ការដាំដំណាំរួមផ្សំក្នុងឃុំ លើផ្ទៃដីប្រមាណ ៩៤ ហិចតា ក្នុងនោះរួមមានៈ ពោត សណ្តែកដី សណ្តែកបាយ ដំឡូងមី ដំឡូងជ្វា អំពៅ និង ដំណាំឈើហូបផ្លែផ្សេងៗទៀត ដែលការដាំដុះទាំងនោះមានលក្ខណៈបែបបុរាណនៅឡើយ ។ ចំណែកការចិញ្ចឹមសត្វស្រុកដូចជា គោ ក្របី ជ្រូក មាន់ ទា និងការចិញ្ចឹមត្រី នៅមានលក្ខណៈជាគ្រួសារនៅឡើយ។

តាមទិន្នន័យ និង ស្ថានភាពខាងលើបញ្ជាក់ឲ្យឃើញថា វិស័យកសិកម្មដែលជាមុខរបរចំបង និងសំខាន់សំរាប់ទ្រទង់ជីវភាពគ្រួសាររបស់ប្រជាពលរដ្ឋនៅក្នុងឃុំមិនទាន់មានការរីកចម្រើនស្របតាមគោលដៅ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជានៅឡើយ ។

ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាឃុំ ក្នុងអាណត្តិទី៣នេះ នឹងផ្តល់អាទិភាពខ្ពស់លើការលើកកម្ពស់ផលិតភាពកសិកម្ម បង្កើនសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់តាមរយៈការបង្វែទិសពីការអភិវឌ្ឍតាមបែបបើកទូលាយ ទៅជាការអភិវឌ្ឍតាមបែបស៊ីជម្រៅ ឬ តាមបែបប្រពលវប្បកម្មដំណាំស្រូវ និង ជំរុញការដាំដំណាំ និង ចិញ្ចឹមសត្វ តាមបច្ចេកទេស និង ការស្រាវជ្រាវពីការអភិវឌ្ឍ សំដៅបង្កើនប្រាក់ចំណូលគ្រួសារ លើកកំពស់ជីវភាពរស់នៅ កាត់បន្ថយភាពក្រីក្រ តាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីររបស់រាជរដ្ឋាភិបាលកម្ពុជា

### ក.២. សកម្មភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវលំជនបទ

នៅក្នុងឃុំតានីមានបណ្តាញប្រព័ន្ធផ្លូវលំខ្វាត់ខ្វែង ដែលជាគម្រោងអភិវឌ្ឍន៍របស់ ក្រុមប្រឹក្សាឃុំអាណត្តិទី១ និង អាណត្តិទី២ បានយកចិត្តទុកដាក់ក្នុងការកសាងផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវលំជនបទ ដែលជាសរសៃឈាមសេដ្ឋកិច្ច តភ្ជាប់ពីភូមិមួយទៅភូមិមួយ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ផ្នែកនេះស្ថិតនៅជាតម្រូវការចាំបាច់ និង មានអាទិភាពខ្ពស់នៅឡើយ ដោយហេតុថា គម្រោងផ្លូវលំជនបទពីមុនមានទំហំទទឹងតូច ផ្លូវក្រាលគ្រួសក្រហមជាច្រើនខ្សែត្រូវខូចសឹករិចរឹល គ្រលុកសំបុកមាន់ ច្រោះដាច់ដោយអន្លើ និង នៅមានផ្លូវជាច្រើនខ្សែច្រើនភូមិទៀតដែលមិនទាន់បានសាងសង់ ថែមទាំងនៅខ្វះលូរំដោះទឹក ប្រព័ន្ធលូបង្ហូរទឹកសំរាប់ការពារផ្លូវលំនោះផង។

ទោះជាយ៉ាងនេះក្តី ក៏ក្រុមប្រឹក្សាឃុំក្នុងអាណត្តិទី៣នេះ និង ផ្តល់អាទិភាពខ្ពស់លើការស្តារ និង កសាងប្រព័ន្ធគមនាគមន៍ផ្លូវលំជនបទ រួមមានផ្លូវក្រាលគ្រួសក្រហម ផ្លូវលំដីស ដោយគ្រេងយកដីភ្នំធ្វើការសាងសង់ លូរំដោះទឹក ស្ពាន និង ប្រព័ន្ធបង្ហូរទឹកការពារផ្លូវ ព្រមទាំងផ្តោតលើការថែទាំផ្លូវលំ ស្របតាមគោលនយោបាយដឹកជញ្ជូន របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងឆ្នាំ២០១៥ កន្លងមកនេះ ឃុំតានីបានជួយដោះស្រាយបញ្ហាលំបាកជូនប្រជាពលរដ្ឋក្នុងភូមិមួយចំនួន ដែលជួបនឹងបញ្ហាលំបាកក្នុងការធ្វើដំណើរ ហើយបានដោះស្រាយរួចរាល់ជាស្ថាពរក្នុងឆ្នាំ២០១៥នេះគឺបានលើកផ្លូវចំនួនបីខ្សែជូនប្រជាពលរដ្ឋចំនួនបីភូមិដែរ

មានដូចជា៖

- លើកផ្លូវដីសក្នុងភូមិត្រពាំងរាំង
- លើកផ្លូវដីសក្នុងភូមិតាកុក
- និងលើកផ្លូវដីគ្រួសក្រហមក្នុងភូមិឫស្សី ដោយមានការគាំទ្រពីក្រុមប្រឹក្សាឃុំ និង ប្រជាពលរដ្ឋក្នុងភូមិនីមួយៗ ។

### ក.៣. សកម្មភាពការងារធនធានទឹក

ឃុំតានី ពុំមានប្រព័ន្ធធារាសាស្ត្រ ខ្នាតតូច មធ្យម ធំអ្វីឡើយ ។ ទំនប់ ប្រឡាយដែលនៅសេសសល់ពីរបបប៉ុលពតត្រូវបានខូចខាតអស់ ដោយសារប្រជាពលរដ្ឋរុករានទន្រ្ទានកាន់កាប់ធ្វើភូមិសម្រាប់ការរស់នៅ ធ្វើចំការ ដាំដំណាំ លើខ្នងទំនប់ ធ្វើស្រែក្នុងប្រឡាយ ក្នុងអាងទំនប់ដែលជាឧបសគ្គក្នុងការស្តារ និង ជួសជុលឡើវិញ នូវប្រព័ន្ធស្រោចស្រពទាំងនោះ។

បច្ចុប្បន្ននេះនៅមានភូមិ០២ ក្នុងចំណោមភូមិទាំង០៧ ក្នុងឃុំតានី នៅមានប្រឡាយដែលនៅសល់ពីរបបប៉ុលពត ទទួលបានគម្រោងក្នុងការស្តារឡើងវិញជូនប្រជាពលរដ្ឋក្នុងភូមិ ទាំង០២ នោះ គឺភូមិឫស្សី និង ភូមិប្រាល ។ ហើយគម្រោងស្តារប្រឡាយគឺធ្វើឡើងដើម្បីផ្ទុកទឹក សម្រាប់ស្រោចស្រពដំណាំ និង ស្រូវប្រាំងក្នុងរដូវប្រាំងជូនប្រជាពលរដ្ឋក្នុងភូមិនោះ។

### ក.៤. ផ្នែកឧស្សាហកម្ម និងថាមពល

ក្នុងឃុំតានី មានបណ្តាញអគ្គីសនី ផ្តល់ថាមពលដល់ប្រជាពលរដ្ឋក្នុងឃុំទាំង០៧ភូមិ ។ នៅក្នុងឃុំតានីក៏មានសិប្បកម្មខ្នាតតូចផងដែរដូចជា: ម៉ាស៊ីនកិនស្រូវខ្នាតតូច សិប្បកម្មផ្សារដែក ដែលជាមូលដ្ឋានអាជីវកម្មទាំងនោះខ្លះមានច្បាប់អនុញ្ញាតត្រឹមត្រូវ ។

ក្រុមប្រឹក្សាឃុំតានីក្នុងអាណត្តិទី៣នេះ និង ខិតខំយកចិត្តទុកដាក់ជម្រុញការផ្តល់សេវាអគ្គីសនីក្នុងតំលៃសមស្រប ជម្រុញការពង្រីកបណ្តាញតភ្ជាប់ និង ប្រើប្រាស់បានកាន់តែទូលំទូលាយយកចិត្តទុកដាក់លើអាជីវកម្មខ្នាតតូចឲ្យមានការវិវត្តន៍ សំដៅបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងឃុំឲ្យកាន់តែល្អប្រសើរ ។

## ខ.លទ្ធផលនៃកិច្ចប្រតិបត្តិការផ្នែកសង្គមកិច្ច

### ខ.១. ការងារផ្នែកវិស័យអប់រំ

នៅទូទាំងឃុំតានី មានសាលាមត្តេយ្យ ៥សាលាស្មើនឹង ៥ថ្នាក់ ក្នុងនោះមានកុមារអាយុពី៣ទៅ៥ ឆ្នាំបានចូលរៀន ២៧៧នាក់។ សាលាបឋមសិក្សាមាន៥សាលា ស្មើនឹង ៥៥បន្ទប់ ឬស្មើនឹង ៥៥ថ្នាក់ សិស្សកំពុងរៀន ១.៩៩៩នាក់ ។ និងសាលាអនុវិទ្យាល័យ ១សាលា ស្មើនឹង ២៨បន្ទប់ ឬស្មើនឹង ២១ថ្នាក់ ចំនួនសិស្សសរុបកំពុងរៀនមាន ៨២៧នាក់ ។

ក្រុមប្រឹក្សាឃុំ បានយកចិត្តទុកដាក់អនុវត្តន៍ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើការអប់រំមូលដ្ឋាន (ពីថ្នាក់ទី១ ដល់ថ្នាក់ទី៩) និង ជម្រុញលើកទឹកចិត្តគ្រូបង្រៀន និង សិស្សពូកែ ផ្តល់សម្ភារៈបរិក្ខា ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រ ដើម្បីកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្សានុសិស្ស ។

## ខ.២. សកម្មភាពផ្នែកសុខាភិបាល

តាមទិន្នន័យខាងលើនេះបង្ហាញថា ប្រព័ន្ធផ្តល់សេវាសុខភាពក្នុងឃុំ នៅមានការខ្វះខាតនៅឡើយ ព្រោះថា មណ្ឌលសុខភាពមានចំនួនតិច ហើយភូមិរបស់ប្រជាពលរដ្ឋភាគច្រើនគឺស្ថិតនៅឆ្ងាយពីមន្ទីពេទ្យបង្អែក និង មណ្ឌលសុខភាព។

ទោះជាយ៉ាងនេះក្តី ក៏ក្រុមប្រឹក្សាឃុំតានី អាណត្តិទី៣នេះ បានយកចិត្តទុកដាក់ លើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដើម្បីធ្វើឲ្យកាន់តែល្អប្រសើរឡើយ នូវសុខភាព និង សុខមាលភាពរបស់ប្រជាពលរដ្ឋ ពិសេសជនក្រីក្រ គ្រួសារងាយរងគ្រោះ ស្ត្រីនិងកុមារ រួមទាំងអនុវត្តគោលដៅកាត់បន្ថយអត្រាស្លាប់របស់មាតានិងទារក ពង្រឹងសេវាសុខភាពបន្តពូជ សេវាសុខភាពមាតាទារក និងកម្មវិធីបង្ការជំងឺឆ្លងផ្សេងៗ ។

## ខ.៣. សកម្មភាពផ្នែកអភិវឌ្ឍន៍ជនបទ

រយៈពេលកន្លងមក នៅឃុំតានីមានអណ្តូង ១៣០អណ្តូង ក្នុងនោះមានអណ្តូងខួង ១១៣ អណ្តូង អណ្តូងជីកមានការការពារ ១៤អណ្តូង អណ្តូងជីកគ្មានការការពារ ៣អណ្តូង ។ ក្នុងឃុំតានីមានប្រព័ន្ធទឹកស្អាតផ្តល់សេវាជូនប្រជាពលរដ្ឋក្នុងឃុំ មានភូមិឫស្សី ភូមិប្រាល តាមទិន្នន័យខាងលើនេះ គឺប្រជាពលរដ្ឋប្រមាណជាជាង ៣៥% មិនទាន់មានការយល់ដឹងអំពីអនាម័យប្រើប្រាស់ និង ហូបទឹកស្អាត ។ នៅតាមបណ្តាភូមិ ប្រជាពលរដ្ឋប្រមាណ ១.០៥៥គ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់។

ក្រុមប្រឹក្សាឃុំតានី អាណត្តិទី៣នេះ បានផ្តោតការយកចិត្តទុកដាក់ក្នុងការប្រើប្រាស់ និង ទទួលទានទឹកស្អាត តាមរយៈការផ្គត់ផ្គង់ទឹកស្អាត និងពង្រីកបណ្តាញប្រើប្រាស់ទឹក ការជីកអណ្តូងទឹកស្អាត ការជួសជុសអណ្តូងទឹកស្អាតឲ្យដំណើរការល្អឡើងវិញ ជំរុញការប្រើប្រាស់ធុងចំពោះទឹកស្អាត និង ជំរុញការប្រើប្រាស់បង្គន់អនាម័យ សំដៅធានាអនាម័យក្នុងសហគមន៍ និង លើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋនៅមូលដ្ឋាន តាមពាក្យស្លោកថា« ផឹកស្អាត ហូបស្អាត រស់នៅស្អាត»។

## ខ.៤. កិច្ចការសង្គម

ស្ថានភាពសង្គមនៅក្នុងឃុំតានី គ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន ១២.៥០% គ្រួសារដែលមានផ្ទុកមេរោគអេដស៍ចំនួន ១៦គ្រួសារ កុមារកំព្រាក្រោមអាយុ ១៨ឆ្នាំមានចំនួន ១០

នាក់ជនពិការចំនួន ៩៣នាក់គ្រួសារដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារមានចំនួន៦គ្រួសារ។ ក្រុមប្រឹក្សាឃុំតានី និង គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ បានជ្រើសរើសគ្រួសារទីទ័លក្របានចំនួន០៦ គ្រួសារទទួលអំណោយពីថ្នាក់ខេត្ត និង បានធ្វើប័ណ្ណសមធានជូនគ្រួសារក្រីក្របានចំនួន១៣០គ្រួសារ។

## គ. លទ្ធផលនៃកិច្ចប្រតិបត្តិការផ្នែកធនធានធម្មជាតិ និងបរិស្ថាន

### គ.១. ការគ្រប់គ្រងដីធ្លី

ឃុំ តានី បានទទួលគម្រោងវាស់វែងដីធ្លីជាលក្ខណៈប្រព័ន្ធចាប់ពីឆ្នាំ ២០០៥មក គ្រោងនេះបានចាប់ផ្តើមវាស់វែងដីភូមិ ដីស្រែ ដីចំការជូនប្រជាពលរដ្ឋ និង ដីសាធារណៈរបស់ឯកជន ដីសាធារណៈរបស់រដ្ឋ និង ចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងជូនតំណាងអង្គការសាធារណៈសម្រេចបាន១០០%។

នៅចំពោះមុខ ក្រុមប្រឹក្សាឃុំ បានផ្តោតជាសំខាន់ទៅលើប្រព័ន្ធគ្រប់គ្រង និង ការប្រើប្រាស់ដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លី លុបបំបាត់ភាពអាណាធិបតេយ្យក្នុងការកាន់កាប់ដីធ្លីដោយខុសច្បាប់ ធ្វើការអប់រំផ្សព្វផ្សាយអំពីច្បាប់ភូមិបាល និង ច្បាប់ផ្សេងៗទៀត លើកកម្ពស់ការយល់ដឹងរបស់ប្រជាជន ព្រមទាំងការគាំទ្រ និង បង្កើតសហគមន៍ព្រៃឈើ នៅតំបន់ជាប់ជើងភ្នំផងដែរ។

### គ.២. ធនធានធម្មជាតិ និងបរិស្ថាន

ក្នុងភូមិសាស្ត្រឃុំ តានី គឺជាតំបន់កូនភ្នំ ដូចជាភ្នំ សែនហាន ភ្នំត្រែល ភ្នំសាយ៉ា ហើយភ្នំទាំងនេះ សំបូរទៅដោយធនធានធម្មជាតិមានរ៉ែផ្សេងៗដូចជា ថ្ម ដីគ្រួសក្រហម និង ធម្មជាតិស្រស់ត្រកាល ។ ព្រមជាមួយនេះភូមិសាស្ត្រឃុំ ក៏មានបឹងមួយកន្លែងផងដែរ ដែលស្ថិតនៅប៉ែកខាងកើតជាប់ព្រំប្រទល់ ស្រុកទ្រាំង ខេត្តតាកែវ ។ ក្រុមប្រឹក្សាឃុំតានីបានប្រជុំផ្សព្វផ្សាយមិនឲ្យះ

- ប្រជាពលរដ្ឋ កាប់គាស់ដីព្រៃ និង ការពារមិនឲ្យមានភ្លើងឆេះព្រៃ
- បានបំបាត់អំពើឆក់ត្រីតាមភូមិ

### គ.៣. ការប្រែលប្រួលអាកាសធាតុ និង គ្រោះមហន្តរាយ

ជាទូទៅ ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្ន តែងតែបានជួបទៅនឹងការប្រែលប្រួលអាកាសធាតុដូចជា: ការកើនឡើងកំដៅខ្លាំង ត្រជាក់ខុសប្រក្រតី រដូវប្រាំងអូសបន្លាយរយៈពេលយូរ ភ្លៀងធ្លាក់ខុសរដូវជាដើម។ ជាងនេះទៅទៀតមានគ្រោះទឹកជំនន់កើតឡើងជារៀងរាល់ឆ្នាំ។

## ឃ.លទ្ធផលនៃកិច្ចប្រតិបត្តិការផ្នែកសេវារដ្ឋបាល និងសន្តិសុខ

### ឃ.១. ផ្នែករដ្ឋបាល

ក្នុងឃុំតានី មានគ្រួសារចំនួន ២.៣៨៦គ្រួសារ មានចំនួនប្រជាជនសរុប ១១.១៤៨នាក់ ក្នុងនោះមានស្រី ៥.៨៦៨នាក់ ដែលមានទីលំនៅជាអចិន្ត្រៃយ៍ក្នុងភូមិ ឃុំនៃដែនសមត្ថកិច្ចរបស់ឃុំ

តានី។ ហើយបច្ចុប្បនេះការផ្តល់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត នៅបន្តអនុវត្តជូន ប្រជាពលរដ្ឋយ៉ាងយកចិត្តទុកដាក់បំផុត ។ បានអញ្ជើញប្រជាពលរដ្ឋអាយុ១៥ ឆ្នាំឡើង មិនទាន់មានអត្តសញ្ញាណប័ណ្ណមកធ្វើអត្តសញ្ញាណប័ណ្ណ ។ ប៉ុន្តែនៅទីកន្លែងធ្វើការរបស់រដ្ឋបាលឃុំ គ្មានភាពងាយស្រួល ព្រោះនូវខ្វះសាលាឃុំ ខ្វះសំភារៈការិយាល័យ ដូចជាកៅអីជ័រ នៅពេលប្រជុំ ដែលមានប្រជាពលរដ្ឋច្រើនចូលរួម។

លទ្ធផលការងារផ្នែកអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សំបុត្រកំណើត | ១៨៣ |
| ២ | សំបុត្របញ្ជាក់កំណើត | ១៨០ |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត | ១៥ |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ៧៩ |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៣០ |
| ៧ | សំបុត្រមរណភាព | ៣៣ |
| ៨ | សេចក្តីសម្លងសំបុត្រមរណភាព | ១៤ |

### ឃ.២. ផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

នៅឆ្នាំ២០១៥ កន្លងមកក្នុងឃុំមិនមានករណីប្លន់កើតឡើងនោះទេ ប៉ុន្តែនៅមានករណីលួចកាច់សោរ.កម៉ូតូ លួចគាស់ផ្ទះយករបស់របរ ក្រុមក្មេងទំនើងវាយប្រកាប់ប្រចាក់គ្នា ករណីចាប់រំលោភសេពសន្ថវៈ និង ករណីគ្រោះថ្នាក់ចរាចរណ៍តែងតែកើតមានឡើងជារឿយៗ។ ប៉ុន្តែ បច្ចុប្បន្នដោយមានការខិតខំយកចិត្តទុកដាក់ ក្នុងការអនុវត្តគោលការណ៍ភូមិ ឃុំមានសុវត្ថិភាព និងប្រជាការពារ ចុះធ្វើសកម្មភាពយាមល្បាតតាមភូមិ និងចុះជួយយាមការពារម៉ូតូជូនប្រជាពលរដ្ឋ គ្រប់កម្មវិធី នាំឲ្យសកម្មភាពមួយចំនួនខាងលើមានភាពស្ងប់ស្ងាត់។

### ខ.លទ្ធផលនៃកិច្ចប្រតិបត្តិការផ្នែកយេនឌ័រ

ដោយយោងទៅលើការវិភាគក្នុងព័ត៌មានស្ថានភាពឃុំ សូចនាករតាមវិស័យ ផែនទីរដ្ឋបាលសៀវភៅទិន្នន័យភូមិ ឃុំ សូចនាករគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា របាយការណ៍ផែនការអភិវឌ្ឍន៍ឃុំអាណត្តិមុន ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចលើកទី២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានបង្ហាញឲ្យឃើញថាឃុំបានទទួលលទ្ធផលការងារល្អក្នុងផ្នែកយេនឌ័រ ហើយលទ្ធ

ផលទាំងនេះបានបង្កលក្ខណៈដល់ឃុំក្នុងការរៀបចំនូវកម្មវិធីវិនិយោគរយៈពេល ១ឆ្នាំខាងមុខនេះ និង ដោះស្រាយបាននូវបញ្ហាប្រឈមមុខនានាឆ្លើយតបទៅនឹងសេចក្ដីត្រូវការពិតប្រាកដជូនដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ។ គណៈកម្មាធិកាទទួលបន្ទុក កិច្ចការនារី និងកុមារ បានចុះប្រជុំលើកកម្ពស់សុខភាពមាតា និងទារក ទាំង០៧ ភូមិ ទូទាំងឃុំ និងបានណែនាំបំបាត់អំពើហឹង្សាក្នុងគ្រួសារបាន ៥០គ្រួសារ។

ម៉្យាងវិញទៀតការរៀបចំគម្រោងអភិវឌ្ឍន៍នេះ គឺដោយមានការចូលរួមពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ និងមានការសម្របសម្រួល ពីមន្ត្រីការិយាល័យផែនការគាំទ្រឃុំ សហការជាមួយមន្ត្រីជំនាញផែនការ ក្រុង ស្រុក ខណ្ឌ អង្គការមិនមែនរដ្ឋាភិបាក និង អ្នកពាក់ព័ន្ធនានា ដោយមានការចូលរួមផ្ដល់យោបល់ លើកឡើងពីបញ្ហា និង តម្រូវការពីប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានផ្ទាល់។

### ៣.២.បញ្ហាប្រឈម

ទោះបីជាឃុំមានឱកាសក្នុងការអភិវឌ្ឍមូលដ្ឋានក្នុងភូមិ ឃុំរបស់ខ្លួន លើគ្រប់ផ្នែកទាំងអស់ក៏ដោយ ក៏យើងសង្កេតឃើញថា នៅតែមានចន្លោះខ្វះខាត ដែលឃុំពុំទាន់បានធ្វើការឆ្លើយតបទៅនឹងបញ្ហានានាមួយចំនួនដែលចោទមានឡើង។ ហើយបញ្ហាដែលចោទមានឡើងនោះ ឃុំកំពុងតែស្វះស្វែងរកដំណោះស្រាយជូនប្រជាពលរដ្ឋដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ បញ្ហាទាំងអស់នោះរួមមានទៅលើផ្នែកៈ

**ផ្នែកសេដ្ឋកិច្ច** នៅមានបញ្ហាប្រឈមមុខជាច្រើនដែលត្រូវដោះស្រាយដូចជា៖

- ប្រព័ន្ធធារាសាស្ត្រពុំទាន់បានកែលម្អ និង ជួសជុលតាមតំរូវការរបស់ប្រជាពលរដ្ឋនៅឡើយ
- ការចិញ្ចឹមសត្វដូចជា គោ ជ្រូក មាន់ ទា ពុំទាន់មានបច្ចេកទេសត្រឹមត្រូវ ខ្វះដើមទុន ខ្វះដៃគូរសហការក្នុងការលក់ចេញ ទិញចូល។
- ចំពោះប្រព័ន្ធផ្លូវលំក្នុងឃុំវិញប្រឈមនឹងការជួសជុលថែទាំផង និង សាងសង់ថ្មីផង។

ហើយដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើឃុំបានលើកឡើងនូវគម្រោង ឬ សកម្មភាព អាទិភាពដូចជាៈ លើកផ្លូវដីក្រាលគ្រួសក្រហម គម្រោងជួសជុលថែទាំផ្លូវគ្រួសក្រហម ស្ពារប្រឡាយ ជួសជុលទំនប់ ស្ពារស្រះស្រោចស្រព និង បច្ចេកទេសកសិកម្មផ្សេងៗ ដែលបម្រើឲ្យផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ០៧ភូមិទូទាំងឃុំ។

**ផ្នែកសង្គមកិច្ច** នៅមានបញ្ហាប្រឈមមុខជាច្រើនដែលត្រូវដោះស្រាយដូចជាៈ

- ខ្វះសាលារៀន (បឋមសិក្សា និង អនុវិទ្យាល័យ)

- កុមារបោះបង់ការសិក្សា ពីអាយុ ១២ឆ្នាំ ទៅ អាយុ ១៥ឆ្នាំ
- មណ្ឌលសុខភាពនៅឆ្ងាយពីភូមិមួយចំនួនតូចក្នុងឃុំ
- មិនយល់ពីសារៈសំខាន់នៃសុខភាព និង អនាម័យ
- ខ្វះប្រភពផ្គត់ផ្គង់ទឹកស្អាត
- ខ្វះបង្គន់អនាម័យ

ក្រៅពីនេះក៏នៅមានបញ្ហាជាច្រើនទៀតដូចជា គ្រួសារដែលមានសមាជិកកើតអេដស៍ កុមារកំព្រាដោយសារជំងឺអេដស៍ កុមារកំព្រាករណីទូទៅ ចាស់ជរាគ្មានទីពឹង ជនពិការ ស្ត្រីមេម៉ាយ។ ហើយដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើនេះឃុំបានលើកឡើងនូវគម្រោង ឬ សកម្មភាពអាទិភាពដូចជាៈ សាងសង់សាលារៀន អប់រំឪពុកម្តាយឲ្យយល់ពីតំលៃនៃការសិក្សាផ្តល់ អាហារូបករណ៍ដល់សិស្សក្រីក្រ ដែលបម្រើឲ្យផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ០៧ភូមិទូទាំងឃុំ ។

**ផ្នែកធនធានធម្មជាតិ និងបរិស្ថាន** នៅមានបញ្ហាប្រឈមមុខជាច្រើនដែលត្រូវដោះស្រាយដូចជាៈ

- ទំនាស់ដណ្តើមកាន់កាប់ដើមឈើ
- ទាំនាស់អំពីព្រំប្រទល់ដីបន្តិចបន្តួច
- ទំនាស់អំពីការដណ្តើមកាន់កាប់ដីសាធារណៈ

ពេលបច្ចុប្បន្ន ព្រៃឈើ ភ្នំ ព្រៃលិចទឹកក្នុងបឹងធម្មជាតិ ត្រូវបានមនុស្សកាប់បំផ្លាញរុករានយកដីធ្វើជាកម្មសិទ្ធិ និង លក់បន្តទៅឲ្យពួកមូលធន ជីកគាស់កកាយធ្វើអាជីវកម្ម បាត់បង់អស់សោភ័ណ្ឌភាពប៉ះពាល់ដល់បរិស្ថាន និង ធនធានធម្មជាតិយ៉ាងធ្ងន់ធ្ងរ។

**ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ** នៅមានបញ្ហាប្រឈមមុខជាច្រើនដែលត្រូវដោះស្រាយដូចជាៈ

- ការចូលមកស្នាក់នៅក្នុងឃុំដោយពុំមានច្បាប់ទម្លាប់
- ការសង់សំណង់អនាធិបតេយ្យលើដីសាធារណៈ
- ចោរកម្មក្នុងឃុំ
- បញ្ហាទំនាស់ដីធ្លីដែលកើតឡើងដោយសារ ពុំទាន់យល់អំពីច្បាប់ភូមិបាល និង ទំនាស់ព្រំប្រទល់ និង ការរំលោភបំពានយកដីសាធារណៈ។

ទំនាស់ផ្សេងៗដែលកើតឡើងដោយសារ បទល្មើសរំលោភច្បាប់ ខ្វះការយោគយល់អធ្យាស្រ័យគ្នា។

**ផ្នែកយេនឌ័រ** នៅមានបញ្ហាប្រឈមមុខជាច្រើនដែលត្រូវដោះស្រាយដូចជាៈ អំពើ

ហឹង្សាក្នុងគ្រួសារ ភាពក្រីក្រ កុមារបោះបង់ការសិក្សា ការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និង រាប់រងបញ្ហាសង្គមមួយចំនួនដែលបន្សល់ទុកដូចជាៈ អ្នកផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ កុមារកំព្រា និង ស្ត្រីមេម៉ាយ។

បញ្ហាទាំងអស់នេះហើយ ដែលទាមទារឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍នានាក្នុងការគាំទ្រដល់កិច្ចអភិវឌ្ឍន៍នៅក្នុងឃុំ ធានាឲ្យមានការឆ្លើយតបដល់សាធារណៈ និង អភិបាលកិច្ចល្អ នៅក្នុងមូលដ្ឋានជូនប្រជាពលរដ្ឋទៅតាមតម្រូវការពិតប្រាកដរបស់ពួកគាត់ ពិសេសផ្តល់ផលប្រយោជន៍ដល់ជនងាររងគ្រោះ ស្ត្រី និង កុមារក្នុងកម្មវិធីអភិវឌ្ឍន៍នេះ។

### ៣.៣. ទិសដៅសកម្មភាពឆ្នាំ២០១៦

កម្មវិធីវិនិយោគឃុំ តានី ឆ្នាំ២០១៦ បានរៀបចំឡើងដោយជ្រើសរើសគម្រោងជាអាទិភាពបំផុតរបស់ប្រជាពលរដ្ឋក្នុងឃុំ ដែលមានថវិកាចំនួន ៥២.៦០៥.០០០ រៀលដោយប្រើប្រាស់ផ្តោតសំខាន់ទៅលើៈ

- គម្រោង ផ្លូវដី ១ខ្សែ និងលូ
- គម្រោងស្តារស្រះភូមិប្រាល
- គម្រោងថែទាំផ្លូវលំ ដែលអនុវត្តដោយអង្គការសហគមន៍មូលដ្ឋាន ៤សហគមន៍[២៤]។

ការលើកទិសដៅសកម្មភាពបន្តឆ្នាំ២០១៦ ទៅលើគម្រោងស្តារស្រះភូមិប្រាលនេះ គឺជាតម្រូវការចាំបាច់ ហើយក៏ជាគម្រោងអាទិភាពជាងគេក្នុងចំណោមគម្រោងទាំងអស់ដែលបានលើកឡើង ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ កំពុងរងការខ្វះខាតទឹកប្រើប្រាស់។ ឧទាហរណ៍ៈ ក្នុងឆ្នាំ២០១៦នេះ មានអាកាសធាតុក្តៅខ្លាំង មិនថាតែនៅក្នុងស្រុក អង្គរជ័យខេត្តកំពត និងខេត្តនានាក្នុងប្រទេសកម្ពុជាទាំងមូលទេ ក៏ដូចជានៅបណ្តាប្រទេសនានា មួយចំនួនដែលទទួលរងនូវគ្រោះរាំងស្ងួតអូសបន្លាយ អាកាសធាតុក្តៅខ្លាំង ប្រជាពលរដ្ឋខ្វះទឹក ប្រើប្រាស់។

ប្រជាពលរដ្ឋ ដែលរស់នៅក្នុងភូមិប្រាលឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ត្រូវការទឹក មិនមែនតែក្នុងឆ្នាំ២០១៦ នេះទេ នៅឆ្នាំកន្លងមកក៏មានការខ្វះខាតដែរ តែឆ្នាំកន្លងមក មានការខ្វះខាតតិចតួច ដោយសារមាន ភ្លៀងធ្លាក់ជាហូរហែរ ដោយឡែកការលើកឡើងគម្រោងស្តារស្រះភូមិប្រាល ក៏មិនមែនទើបតែលើក នៅក្នុងឆ្នាំ២០១៦ នេះដែរ គឺប្រធានក្រុមប្រឹក្សាឃុំ តានី បានលើកគម្រោងនេះតាំងពីឆ្នាំ២០១៥ មកម្លេះ។ ក្រុមប្រឹក្សាឃុំ តានី បានខិតខំប្រឹងប្រែង យកចិត្តទុកដាក់ស្វះស្វែងរកវិធីសាស្ត្រធ្វើយ៉ាងណារកដំណោះស្រាយ ឆ្លើយតបទៅនឹងបញ្ហា និង តម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានភូមិ ឃុំរបស់ខ្លួន បានទាន់ពេលវេលា និងមានប្រសិទ្ធភាពបំផុត។

[២៤] សៀវភៅផែនការអភិវឌ្ឍន៍ឃុំតានី ឆ្នាំ២០១៥

# សេចក្ដីសន្និដ្ឋាន

នៅក្នុងបរិបទជុំវិញទ្រឹស្ដី អភិបាកិច្ចល្អ គឺបានបង្ហាញអំពីលក្ខណៈទាំង៩ ក្នុងដំណើរនៃការធ្វើឲ្យមានអភិបាលកិច្ចល្អ ។ ចំពោះការស្វែងយល់អំពីអភិបាលកិច្ចល្អ ក្នុងក្របខណ្ឌរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ គឺត្រូវពិនិត្យទៅលើនិយមន័យជាសាមញ្ញ ពោល គឺជាវិធីសាស្ត្រក្នុងការគ្រប់គ្រង និង ប្រើប្រាស់ធនធានទាំងឡាយរបស់ឃុំ ដើម្បីបម្រើឲ្យផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន។

តាមរយៈផែនការកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត បានតម្រូវឲ្យ ក្រុមប្រឹក្សាឃុំតានី មេឃុំតានី ជំទប់ទី១ ជំទប់ទី២ ស្មៀនឃុំ មេភូមិ អនុប្រធាន និងសមាជិកភូមិដែលស្ថិតក្រោមឱវាទរដ្ឋបាលឃុំ សង្កាត់ សុទ្ធតែមានការងារទទួលខុសត្រូវយ៉ាសកម្មទាំងអស់គ្នា។ ក្នុងនោះរួមមានៈ

មេឃុំ តានី ដើរតួនាទីពីរប្រភេទ ជាប្រធានក្រុមប្រឹក្សាឃុំផង និងមេឃុំ ផង។ មេឃុំ ជាអ្នកអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ ជាអ្នកអនុវត្តបទប្បញ្ញត្តិ និង គោលការណ៍នានាដែលក្រុមប្រឹក្សាឃុំ បានដាក់សំណើរឡើង ជាអ្នករាយការណ៍ និង ជាអ្នកផ្ដល់យោបល់ដល់ក្រុមប្រឹក្សាឃុំដែរ ហើយមេឃុំ ក៏ជាអ្នកដែលមានសិទ្ធិអំណាចនៅក្នុងដំណើរការនៃការចាត់តាំងគណៈកម្មាធិកានានាផងដែរ ។ មេឃុំ ធ្វើយ៉ាងណាបំផុសការយល់ដឹងពីតម្រូវការរបស់ប្រជាពលរដ្ឋ និង ឆ្លើយតបទៅនឹងតម្រូវការនោះបានយ៉ាងមានប្រសិទ្ធភាព។

ក្រុមប្រឹក្សាឃុំ តានីមានម្នាក់ជាប្រធានក្រុមប្រឹក្សា។ ប្រធានក្រុមប្រឹក្សាឃុំ ទទួលខុសត្រូវក្នុងដំណើរការនៃអង្គប្រជុំ ដោយធ្វើជាអធិបតីដឹកនាំអង្គប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ យ៉ាងតិចមួយដងក្នុងមួយខែ ដើម្បីស្វែងរកចំណាត់ថ្នាក់ភូមិដែលមានអាទិភាពក្នុងការទទួលបានគម្រោងអភិវឌ្ឍន៍ឆ្លើយតបទៅនឹងតម្រូវការនោះ។ សមាជិកក្រុមប្រឹក្សាឃុំ ជាអ្នកបញ្ចេញមតិយោបល់ក្នុងអង្គប្រជុំ មានសិទ្ធិលើកឡើងពីសំណើររបស់ប្រជាពលរដ្ឋនៅក្នុងអង្គប្រជុំ។

ជំទប់ទី១ ជំទប់ទី២ ជាជំនួយការរបស់មេឃុំ គ្រប់គ្រងទៅលើផ្នែកផ្សេងៗគ្នា ដែលជួយសម្រួលដល់ការងារមេឃុំ ធ្វើកិច្ចការជូនប្រជាពលរដ្ឋ នៅពេលដែលប្រជាពលរដ្ឋបានមកពឹងពរឲ្យជួយដោះស្រាយបញ្ហាលំបាកកើតមានឡើង ដែលពួកគាត់ពុំអាចសម្របសម្រួលគ្នាបាន។

ស្មៀនឃុំ ទទួលខុលត្រូវលើការទុកដាក់រៀបចំឯកសារ កំណត់ហេតុ របៀបវារៈនៃកិច្ចប្រជុំជាឯកសារដែលបានថតចម្លង ដើម្បីឲ្យសាធារណៈជនពិនិត្យមើល និង ទទួលខុសត្រូវទៅលើកិច្ចការអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ។

មេភូមិ ទទួលខុសត្រូវលើការអនុវត្តកិច្ចការដែលក្រុមប្រឹក្សាឃុំ ឬ មេឃុំ ប្រគល់ឲ្យ ជាអ្នកស្នើសុំយោបល់ និង ផ្តល់យោបល់ទៅដល់ក្រុមប្រឹក្សាឃុំ ឬ មេឃុំ ដើម្បីចាត់ចែង និង សម្របសម្រួលកិច្ចការនៅក្នុងភូមិ ឬ លើកឡើងពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិ និង ធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិរបស់ខ្លួន។

អនុប្រធានភូមិ និងសមាជិកភូមិ ទទួលខុសត្រូវលើកិច្ចការដែលមេភូមិបានប្រគល់ឲ្យ ជួយសម្រួលកិច្ចការមេភូមិក្នុងការបម្រើផលប្រយោជ៍ជូនប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន។

ការបង្កើតផែនការកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ឃុំតានី គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ របស់ប្រជាពលរដ្ឋ នៅក្នុងភូមិសាស្ត្រឃុំ ហើយឲ្យកាន់តែមានប្រសិទ្ធិភាព និង បានល្អប្រសើរ ក្នុងការដឹកនាំរៀបចំគម្រោងផែនការដោយមានទិសដៅច្បាស់លាស់ ។

ជាលទ្ធផលឃុំតានី បានធ្វើឲ្យគ្រប់គម្រោង ផែនការរបស់ឃុំ អាចសម្រេចបានគ្រប់ផ្នែក និង អាចក្តាប់ព័ត៌មានបានគ្រប់ជ្រុងជ្រោយ ពីសភាពការណ៍ និង តម្រូវការចាំបាច់របស់ប្រពលរដ្ឋទូទាំងឃុំ។ ជាក់ស្តែង នាពេលកន្លងមកសមិទ្ធផលជាច្រើនបានសាងសង់ និង កែលម្អបានយ៉ាងល្អប្រសើរ សម្រេចបានជោគជ័យតាមផែនការ និង ធ្វើឲ្យប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានបានយល់ដឹងពីតួនាទីរបស់ខ្លួនក្នុងការចូលរួមក្នុងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដើម្បីទប់ស្កាត់កុំឲ្យមានបទល្មើសកើតឡើងក្នុងភូមិឃុំរបស់ខ្លួន។

# អនុសាសន៍

រដ្ឋបាលថ្នាក់ឃុំ គឺពិតជាចាំបាច់ណាស់ដែលត្រូវមានលទ្ធភាព និង សម្ភារៈគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តតួនាទីរបស់ខ្លួន និង អាចសម្រេចជាលទ្ធផលល្អប្រសើរសម្រាប់សង្គមជាតិ។ ឆ្លងតាមរយៈនេះ ខ្ញុំសូមអនុញ្ញាញបង្ហាញនូវគំនិតយល់ឃើញរបស់ខ្ញុំ ដើម្បីរួមចំណែកកែលម្អលើចំណុចខ្លះៗដូចខាងក្រោមៈ

១.រាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ផ្តោតសំខាន់ទៅលើការសាងសង់សាលាឃុំ ឲ្យមានស្តង់ដា និង ផ្តល់សំភារៈប្រើប្រាស់ឲ្យបានគ្រប់គ្រាន់មានដូចជា កៅអី តុប្រជុំ កុំព្យូទ័រសម្រាប់ប្រើប្រាស់ក្នុងការិយាល័យដែលអាចបង្កលក្ខណៈងាយស្រួលដល់សមាជិកក្រុមប្រឹក្សាឃុំ ឬ ស្មៀនឃុំ ក្នុងការរៀបចំឯកសារនានាបានរហ័ស និងទាន់ពេលវេលា។

២.ដើម្បីឲ្យដំណើរការនៃការបំពេញតួនាទី ឲ្យមានភាពខ្លាំងខ្លារ និង សកម្មឡើង គឺគួរណាតែបំផុសការផ្តល់ហិរញ្ញវត្ថុក្នុងការអភិវឌ្ឍន៍ផែនការ ឃុំ សង្កាត់ឲ្យច្រើនជាងមុន ជាពិសេសគឺប្រាក់បៀវត្សរ៍ នៅថ្នាក់ភូមិ ក៏ដូចជា ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងគោលបំណងលើកកំពស់កម្រិតជីវភាពរស់នៅរបស់ពួកគាត់ឲ្យកាន់តែប្រសើរឡើង។

៣.ជំរុញលើកទឹកចិត្តមន្រ្តីនគរបាលប៉ុស្តិ៍រដ្ឋបាលថ្នាក់ឃុំ ដោយផ្តល់សំភារៈប្រើប្រាស់សម្រាប់ជាមធ្យោបាយឲ្យបានគ្រប់គ្រាន់ ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ជាពិសេសគឺការផ្តល់ប្រាក់បៀវត្សរ៍។

៤.ដើម្បីធានាប្រសិទ្ធិភាពឲ្យភូមិ ឃុំ មានសុវត្ថិភាព គួរតែបង្កើតវិធានការទប់ស្កាត់ បង្ការការពារ និងរារាំងធ្វើយ៉ាងណាកុំឲ្យមានបទល្មើសកើតមានឡើង។

៥. ក្រុមប្រឹក្សាឃុំតានី គួរណាតែ បង្កើនបង្កើតគម្រោងចុះអប់រំផ្សព្វផ្សាយអំពីច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ច្បាប់ភូមិបាល និងច្បាប់នានា ព្រមទាំងទោសទណ្ឌ នៅតាមបណ្តាភូមិនានា ឲ្យ ប្រជាពលរដ្ឋបានយល់ដឹង។

# ឯកសារយោង

## ផ្នែកទ្រឹស្តី

### សៀវភៅ

- សៀវភៅអភិបាលកិច្ចល្អ របស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ ឆ្នាំ២០១០
- សៀវភៅនីតិរដ្ឋបាលទូទៅ របស់អនុបណ្ឌិត ហៀង សាង សាស្រ្តាចារ្យ ផ្នែកនីតិសាធារណៈ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច, បោះពុម្ពលើកទី២ ឆ្នាំ២០១១

## ផ្នែកគតិយុត្ត

### ច្បាប់

- រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ព្រះរាជក្រម នស/រកម/០១៩៦/០៨ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ច្បាប់ភូមិបាល
- ច្បាប់ស្តីពី កិច្ចការពារបេតិកភណ្ឌនិងវប្បធម៌

### ប្រកាស

- ប្រកាសលេខ១៦០៨ ប្រ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ ស្តីពី ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ និង ជំទប់ទី២ នៃឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត
- សេចក្តីសម្រេចស្តីពីការ បង្កើតគណៈកម្មាធិការនិងជំនួយការនានា

### សេចក្តីសម្រេច

- សេចក្តីសម្រេចស្តីពី ការតែងតាំងគណៈកម្មាធិការកសាងផែនការ និង ថវិកាសំរាប់ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- សេចក្តីសម្រេចស្តីពី ការតែងតាំងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ
- សេចក្តីសម្រេចស្តីពី ការតែងតាំងគណៈកម្មាធិការលទ្ធកម្ម
- សេចក្តីសម្រេចស្តីពី ការតែងតាំងគណៈកម្មាធិការដោះស្រាយវិវាទ

### ដីកា

- ដីកាលេខ ០១.ដក ស្តីពី ការកំណត់កម្រៃសេវារដ្ឋបាលរបស់ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត. ក្រុមប្រឹក្សាឃុំតានី

### កម្រងឯកសារសហគមនភាព

- សៀវភៅកម្មវិធីវិនិយោគរបស់ឃុំតានី ឆ្នាំ២០១៤
- សៀវភៅកម្មវិធីវិនិយោគរបស់ឃុំតានី ឆ្នាំ២០១៥
- សៀវភៅកម្មវិធីវិនិយោគរបស់ឃុំតានី ឆ្នាំ២០១៦

## ឯកសារបទបញ្ជាផ្ទៃក្នុង

បទបញ្ជាផ្ទៃក្នុងសម្រាប់ក្រុមប្រឹក្សាឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត និង គណៈកម្មាធិការជំនួយការ

## ការផ្តល់របាយការណ៍របស់ឃុំតានី

- របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលឃុំ សង្កាត់២០១៤
- របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០១៥

## គេហទំព័រ

- http://www.undp.org

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ផែនទី ឃុំតានី

ឧបសម្ព័ន្ធទី២ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ឧបសម្ព័ន្ធទី៣ បទបញ្ជាផ្ទៃក្នុងសម្រាប់ក្រុមប្រឹក្សាឃុំតានីអាណត្តិទី៣

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល
## ឃុំ សង្កាត់

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសជាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖ ។ល។

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវ៖.

សំរេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមាជិកដទៃទៀតដែរ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

មាត្រា ១៤.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម:

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ១៥.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

មាត្រា ១៦.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ៕

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ

- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវចាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះមានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។/.

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

**មាត្រា ២២.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើសពីពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្ដមានុភាព ។

**មាត្រា ២៣.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្ដីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ ។

**មាត្រា ២៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ។៚

# ជំពូកទី ៣
## រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប :

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។៚

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់ អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិ ឱ្យបានសមស្រប ។ល។

**មាត្រា ៣២.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣៣.-**

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

**មាត្រា ៣៤.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

**មាត្រា ៣៥.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។៚

**មាត្រា ៣៦.-**

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

**មាត្រា ៣៧.-**

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្សេងៗតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងបាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៨.-**

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សា ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល.ស.

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ នឹងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.-**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម

ក្រុម.

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤

## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចិរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ល។

មាត្រា ៤៣.-

ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៤៤.-**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសម្ព័ហាភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥.-**

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ
- ប្រៃសណីយ៍និងទូរគមនាគមន៍
- ការពារប្រទេស ល។

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសំរុះសំរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។៚

មាត្រា ៤៩.-

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ៥០.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៥១.-

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យ ពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ល៉ះ

មាត្រា ៥២.-

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះទេឡើយ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- ប៉ាន់ប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចវិលែកអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

មាត្រា ៥៤.-

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។ល។

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតំរូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំលាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

មាត្រា ៥៨.-

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ៥៩.-

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

មាត្រា ៦០.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៦១.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

មាត្រា ៦២.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ៚.

**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន

- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល

- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់

- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន

- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍

- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន

- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៤.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្រ្តនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ៳

**មាត្រា ៦៥.-**

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ កែតម្រូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃរាល់ការអនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួលខុសត្រូវខ្ពស់ ។

**មាត្រា ៦៧.-**

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតម្លៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

**មាត្រា ៦៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតម្លៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៦៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ទាន់ឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ។ល។

៦៥ ...

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្លៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។

## មាត្រា ៧៤.-

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

## មាត្រា ៧៥.-

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមានៈ

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៧៦.-

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។៚.

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្ដល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្ដល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.-**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្ដែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

មូលនិធិឃុំ សង្កាត់បានមកពី :

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការខ្ចីពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំ-ណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.-**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ល។

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្ដីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានារ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯងនិងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យៗបានគង់វង្ស ហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូវបង្កើតឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញ-វត្ថុរបស់ខ្លួនដែលរួមមាន : ន.ត.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ
- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨

## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។/.

ក្នុងករណីបានអនុវត្តបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ល។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្តុះបណ្តាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- វិះរកមធ្យោបាយសំរាប់ផ្តល់ព័ត៌មាននិងគំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្តល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ល.ល.

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៨នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។៚

រាជធានីភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

ស ខេង យូ ហុកគ្រី

លេខ : ៦០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែ ៧ ឆ្នាំ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] តាន់